CEN
CAMBODIA EXPRESS NEWS

# ព្រាត់ស្នេហ៍នៅមណ្ឌលគិរី

និពន្ធដោយមិត្ត
ប្រាជ្ញ-សេង



# សំបុត្រចំហ របស់អ្នកនិពន្ធ

អស់លោកអ្នកនាងអានជាទីមេត្រី ! រឿង "ព្រាត់ស្នេហ៍នៅ មណ្ឌលគិរី" ដែលខ្ញុំបានប្រឹងប្រឹងតែងចងក្រងឡើង តាមការនិទានរបស់លោក តាខ្មៅ ជាជនជាតិខ្មែរលើរបស់យើងម្នាក់ ដែលគាត់បានចំណាយម៉ោងរ៉ាយរាប់ប្រាប់ខ្ញុំបាទកាលជាង ១៣ឆ្នាំ កន្លងទៅហើយ ។

ខ្ញុំបាទបានស្តាប់ចប់កាលណា ហាក់ដូចជាសាច់រឿងនោះ នៅក្តៅងំពេញទ្រូង ធ្វើឱ្យខ្ញុំបាទចងចាំពុំភ្លេច ។ ទើបល្ងាចមួយ ខ្ញុំអង្គុយមុខវាំងមើលចរន្តទឹកហូរបោកបែកផ្កាត្រែង ហូរទៅឆ្ងាយ លារាជធានី លាពន្លឺ ភ្លើងពណ៌ចម្រុះ ។ ខ្ញុំដកបារីពីហោប៉ៅមកអុជកាន់នៅដៃ បង្ហើរអារម្មណ៍ទៅឆ្ងាយ រហូតនឹកឃើញជាថ្មីនូវរឿង **ព្រាត់ស្នេហ៍នៅមណ្ឌលគិរី** ។ ខ្ញុំបាទមិនម្នាទៅកាន់លំនៅរៀបខោអាវ ដងប៉ាកកា ក្រដាស ទាំងយប់ ឡើងកប៉ាល់ទាំងរាត្រីទៅខេត្តក្រចេះ ។ បន្ទាប់មក ខ្ញុំបាទធ្វើដំណើរទៅកាន់ខេត្តមណ្ឌលគិរី ដួងចិត្តខ្ញុំសួររកផ្ទះលោកតាខ្មៅ ។ ប៉ុន្តែដល់ អ្នកស្រុកទាំងនោះ ផ្លាស់របៀបស្លៀកពាក់តាមកាលៈទេសៈអស់ គឺស្លៀកពាក់ដូចបងប្អូនខ្មែរកណ្តាលយើងសព្វថ្ងៃនេះដែរ ។ ខ្ញុំអរសែនអរនឹកកោតសរសើរ ការផ្លាស់ទម្រង់ថ្មី តាមព្រះរាជនយោបាយនៃសម្តេចដ៏ឆ្នើមជាម្លប់ត្រជាក់ របស់កូនចៅព្រះអង្គគ្រប់រូប ។

កាលទៅដល់ហើយ សួររកឈ្មោះតាខ្មៅ បងប្អូនខ្មែរលើយើងជាច្រើនប្រាប់ខ្ញុំបាទដោយសុភាពថា លោកតាខ្មៅស្លាប់បាត់ទៅហើយ. . . ។

ខ្ញុំបាទ ក៏លាបងប្អូនកម្ពុជាលើទៅកាន់ផ្នូរខ្មោចសង្សារទាំងគូភ្លាម ។ ខ្ញុំបាទអង្គុយក្រោមដើមជ្រៃ ចាប់ដងប៉ាកកាមកនិពន្ធរឿងនោះ ឡើងរហូតដល់ចប់ ។

ខ្ញុំបាទសរសេរបណ្តើរ សំឡឹងផ្លូវខ្មោចអភ័ព្វបណ្តើរ ទ្រូងខ្ញុំបាទញ័រចំ ប្រប់ហាក់ដូចជាព្រលឹងអ្នកទាំងពីរជួយផ្តល់ពតិមានយ៉ាងច្បាស់ៗ បញ្ចោឱ្យខ្ញុំបាទ សរសេរកាន់តែបានវែងថែមទៀត។

ហេតុដូចនេះ ខ្ញុំបាទសូមអង្វរករដល់មិត្តអ្នកអានថា ទោះបីពាក្យសំដី ឃ្លា វគ្គ ពុំសូវពិរោះក្បោះក្បាយ សូមមេត្តាខន្តីអភ័យទោសដល់អ្នកនិពន្ធ។ ហើយសូមចាត់ទុកថា រឿងនេះមានការព្រាត់ប្រាស់កំសត់ប្រហាក់ប្រហែល រឿង **ទុំទាវ** របស់ខ្មែរយើងសព្វថ្ងៃនេះដែរ។

ជាទីបំផុត យុវនិពន្ធខ្ញុំបាទញញឹមទទួលនូវពាក្យតិះដៀល ស្ថាបនា (critique constructive) ពីអស់លោកអ្នកនាងគ្រប់នាទី។

មណ្ឌលគីរី ថ្ងៃ ២០ កក្កដា ១៩៦៥

ប្រាជ្ញសេង

## ១ ប្រភពផ្លូវខ្មោច

នៅដើម គ.ស.១៩៥៣ ព្រឹត្តិការណ៍បដិវត្តន៍នៃពង្សាវតាខ្មែរបានបើកទំព័រមាស ចារដោយផ្លែប៉ាកកាទិព្វកត់ត្រានូវពលិកម្មខ្មែរតស៊ូ ទាមទារឯករាជ្យពេញបរិបូណ៍។

កាលនោះ ខ្ញុំជាយុវជនម្នាក់ ស្ម័គ្រចិត្តបំរើប្រទេសជាតិក្នុងកងខេមរភូមិន្ទ។ អសន្តិសុខក្នុងប្រទេស ត្រូវថយឬទ្ធិបន្តិច។ ជាលំដាប់ លុះបានសុខសាន្តត្រាណតាមសេចក្តីស្រេកឃ្លាន និងតាមសេចក្តីប្រាថ្នានៃខេមរៈជនទូទៅកងទ័ពបារាំងសែស បានឈានជើងចេញពីព្រំសីមាខ្មែរ ដោយអាឡោះអាល័យផែនដី

អាណានិគមរបស់វា។ ប៉ុន្តែសត្រូវ **យៀក មិញ** លបវាយធ្មក់ម្តងតាមជាយដែនខេត្ត ក្រចេះ ស្ទឹងត្រែង ដំបន់រ៉ុនសែ ឡាបានសៀក...។

ចំនួន ១៥ថ្ងៃគត់ កងទ័ពខ្មែរត្រូវបញ្ជូនទៅចាំជាអចិន្ត្រៃយ៍នៅអាណាខេត្តទាំងពីរនេះ ទប់ទល់សត្រូវ យៀក មិញ។ ខ្ញុំបាទជាទាហាន ខាងឈ្លបយកការណ៍ មានករណីយកិច្ចក្លាហានអង់អាចបំផុត ដើរ ក្រាប លូន វារ តាមព្រៃព្រឹក្សា កាត់បឹង អូរ ដើម្បីសង្កេតស្ថានការណ៍បញ្ជូនទៅកងសេនាធិការកណ្តាល ។

ថ្ងៃមួយ កងយោធាយើង បានទៅបោះជំរំទ័ពកណ្តាលព្រៃបង្កប់ ទ័ពរង់ចាំទៅដំបន់ រ៉ុន-សែ។ ខ្ញុំមានភារៈជាអ្នកយកការណ៍បើកផ្លូវ ត្រូវបំពេញនាទីជានិច្ច ទៅឆ្ងាយពីជំរំទ័ព។ ខ្ញុំប្រដាប់ដោយអាវុធ កាំភ្លើងខ្លីគ្រាប់បែកជុំវិញចង្កេះ ស្លៀកពាក់ខោអាវស៊ីវិល កាន់ពូថៅ ក្លែងជាអ្នកកាប់ឱសក្នុងព្រៃភ្នំធំធេង។ ខ្ញុំបន្តដំណើរតតញ្ញៀតទៅទិសខាងជើង ដើររុករានទន្ទ្រានព្រៃម្នាក់ឯងមុនគេ។ ភ្លាមនោះឮភេរវរះសញ្ញាប្រោក១ ប្រិប១ ខ្ញុំភ្ញាក់ព្រើតតែងាកទៅឃើញស្នា ទន្សាយ ឈ្លូស ប្រើស បោល យកតែព្រះអាយុ...។

ខ្ញុំរុករុលទៅមុខ ដូចពួកខ្មែរលើស្លៀកប៉ឹងបាំងកេរ្តិ៍ខ្មាស លែងដងខ្លួនទទេ ស្បែកខ្មៅ សក់រួញ១។ ស្ត្រី ស្លៀកសំពត់ខ្លី លើក្បាលជង្គង់ ចងរុំដោះនឹងក្រមា សក់ដល់ស្មា ពាក់ខ្សែអង្កាំភ្លុក ជាខ្សែគាថាការពារសត្រូវ។

ពួកអ្នកស្រុកភ្នំទាំងនោះ កាចណាស់លើកធ្នូ ស្នាតម្រង់មកទ្រូងខ្ញុំប្រុងប្រហារ តែខ្ញុំលើកដៃឡើងស្រែក កម្ពុជា! កម្ពុជា! ខ្ញុំបង្ហាញកាំភ្លើង គ្រាប់បែក ព្រះឆាយាលក្ខណសម្តេចឪ ទើបពួកនោះដាក់អាវុធចុះ រត់ស្រមកចាប់

ឧបករកលើកស្ទួយខ្ញុំឡើងហ៊ោសប្បាយ ខ្លះបេះផ្លែឈើ ឱ្យទឹកឃ្មុំ ខ្លះទៀតយក ស្រាពីបំពងឬស្សីឱ្យខ្ញុំក្រេបផឹក។

-អ្ហា ! ស្រាភ្នងឆ្ងាញ់ណាស់ តែខ្លាំងបន្តិចហើយ!

ខ្ញុំលាពួកមេកន្ទ្រាយទៅមុខទៀត កាត់ព្រៃ កាត់វាល។ ទៅមុខបាន ប្រហែលកន្លះគីឡូម៉ែត្រ ជួបវាក់ស្ទឹងធំមួយ ទឹកថ្លាដូចកញ្ចក់ ហូរចេញពីប្រភព ភ្នំយុកណាំលៀវ ដែលមានកំពស់១១០០ម៉ែត្រ ក្នុងមណ្ឌលគីរីសព្វថ្ងៃ។ ខ្ញុំទាល់ ប្រាជ្ញពុំអាចឆ្លងទៅមុខទៀតបានឡើយ ក៏ប្រថុយដើរសៀវតាមមាត់ស្ទឹង ស្ដាប់ សូរបក្សាបក្សី ស្រែករំពងព្រៃ។ ចចក ស្វាន ស្វា ឈ្លួស បោលកាត់មុខម្ដង១ ឥតងាកក្រោយ។

-អៃយ៉ា ! នរណាអីចេះ ជីកពូនដីធ្វើលេណស្ថាន (ត្រង់សេ) ឬអ្វី ? ខ្ញុំខំលបលូនទៅក្បែរ ស្រាប់តែពួកខ្មែរលើយើង ២ នាក់ សោះ ពូនផ្នូរខ្មោចដ៏ធំ ចំឡែកអស្ចារ្យ ក្រោមដើមជ្រៃបែកមែកសាខាគ្របផ្នូរ។

ខ្ញុំកាត់ចិត្តចូលទៅសួរយកការណ៍ ចង់ដឹងរឿងហេតុចុះម្ដេចក៏ផ្នូរខ្មោច ធំម្ល៉េះ ? ជីករណ្ដៅត្រង់សេឱ្យខ្មាំងរកដឹង ? ដើរទៅជិតមនុស្សស្លៀកវ៉នប៊ីង ទាំងនោះ តម្រង់មុខព្រួយដាក់ទ្រូងខ្ញុំ ប្រុងប្រហារជីវិតខ្ញុំទៀតហើយ។ ខ្ញុំរាដៃ កាត់ បង្ហាញព្រះឆាយាល័ក្ខណ៍ បង្ហាញសក្ដិទាហានខ្មែរ ស្រែកថា កម្ពុជា១។

លុះឮពាក្យ កម្ពុជា ជនទាំងនោះទម្លាក់ស្នាចុះរត់មកចាប់ដៃ សើច ស្ញេញស្ញាញអង្អែលប្រាណខ្ញុំ។ គេនិយាយភាសា ភ្នង ស្មៀង មន យ៉ាងអិះអុះ១ ។ ប៉ុន្ដែដោយខ្ញុំបាទ ចេះភាសាភ្នងក្រាស់ក្រែលដែរ ក៏និយាយស្ដាប់គ្នាបាន គេ យំចាប់ឱបខ្ញុំ ហាក់ដូចស្គាល់គ្នាពីយូរសតវត្សមកហើយដែរ។ ក្រោយមកគេ រៀបបាយវេច ទឹកបំពង់ ស្រា សោម សាច់ថ្លាន់ សាច់ឈ្លួសឱ្យខ្ញុំអាស្រ័យ គេ

អង្គុយមើល ។ ខ្ញុំដែលឃ្លានស្ទើររបោចពោះក៏ចាប់អាស្រ័យបាយចំអែតក្រពះ ។ រួចមកអង្គុយសំណេះសំណាលគ្នាលេង ជាភាសាពួកគេ ។ ខ្ញុំសួរបញ្ជាក់យ៉ាងឆ្ងល់ទៅលោកតាខ្មៅ មាឌក្រអាញម្នាក់អំពីប្រវត្តិផ្នូរខ្មោចធំចំឡែកនោះ ។

តាខ្មៅបានសារភាពរ៉ាយរាប់មកខ្ញុំជាភាសា ស្ទៀង ដែលប្រែមកថា:

-ផ្នូរខ្មោចដ៏ធំសម្បើមនេះ កប់មនុស្សពីរនាក់ប្ដីប្រពន្ធ ជាសង្សារចិត្តមួយថ្លើមមួយ គោរពពាក្យស្បថលុះក្ស័យជីវិត ។

ខ្ញុំឮដូចនោះរឹតតែឆ្ងល់ខ្លាំងឡើង រំជួលចិត្តចាប់អារម្មណ៍ចង់ដឹងតទៅទៀត សួរថែម ។ គាត់ឈប់និយាយ យកដៃជូតទឹកភ្នែកល្អក់ ។ មួយសន្ទុះធំទើបលាន់វាចា :

"បើលោកចង់ដឹងឱ្យជ្រៅជ្រះ ខ្ញុំអាចនិទានបានរឿងនេះពីដើមរហូតចប់ឱ្យស្ដាប់ តែត្រូវចំណាយពេលយូរបន្តិចហើយ !"

ខ្ញុំតបដោយគោរព :

"សូមលោកតា និទានមកចុះ ខ្ញុំបាទស្ដាប់ទាល់តែចប់ ខ្ញុំចង់ដឹង ចង់ឮប្រវត្តិរឿងប្លែកពីបណ្ដាជនពួកភ្នំណាស់ ព្រោះមិនដែលដឹងរឿងរ៉ាវសោះ"

ខណៈនោះ លោកតាខ្មៅស្រិលយកកខ្សៀកញ្ជោមកអុជ ស្រូបបឺតគ្រូកគ្រាក១ ជក់អស់មួយខ្សៀ ទើបចាប់និយាយ ។

ខ្ញុំអង្គុយប្រឹងទាញក្រដាស នឹងដងប៉ាកកា មកកត់យកពាក្យសំខាន់១ វគ្គល្អ១ មកចងក្រងទុកជាឯកសាគ្រាន់និទានជូនបងប្អូនកម្ពុជាកណ្ដាលយើងស្ដាប់ ។

ឯសាច់រឿងកំសត់នោះមានដូចតទៅ :

# ២-ពាក្យស្បថ

...រំលងជាង ២០០ ឆ្នាំ មកហើយ នៅជើងភ្នំយុកណាំល្បៀវ ប៉ែកខាងជើង មាននារីម្នាក់រូបស្អាតលើសគេ ទាំងអស់ក្នុងដំបន់ភ្នំ ។ នាងជាបុត្រីលោកមេកន្ទ្រាញ មណ្ឌលពោះម៉ាយ ។ នាងមានឈ្មោះថា មណ្ឌល-គីរី ជាក្មេងស្រីមានប្រាជ្ញលើសអស់ស្រីៗក្នុងឃុំទាំងមូល ។ នាងមានអាយុ ១៧ ឆ្នាំ ចេះបង្រៀនបង្ហាត់អ្នកស្រុកឱ្យចេះត្បាញសំពត់ រវៃអំបោះ ចេះដេរអាវពាក់ការពារធាតុ ក្តៅ-ត្រជាក់ ។ លុះប្រកបវ័យ ១៨ ឆ្នាំ នាងចេះគ្រប់មុខវិជ្ជាស្រីមេផ្ទះយ៉ាងប៉ិនប្រសប់ ។ ក្នុងអាយុពេញការនេះ លំអរបស់នាងជាប់ពីធម្មជាតិ ព្រៃភ្នំប្រគល់ឱ្យនោះ ធ្វើឱ្យកូនកំឡោះមន ស្មៀង ភ្នង ឯទៀតៗចោមចង់បានស្និគ្ធចិត្តជាបេក្ខជន ប្រឡងកាប់ ចាក់ដណ្តើមគ្នាដណ្តឹងយកជាប្រពន្ធ ។ ប៉ុន្តែមណ្ឌល-គីរី នៅអល់ឯកពុំទាន់ចង់បានប្តីទេ នាងចង់នៅឱ្យសប្បាយបានរយាលយូរឆ្នាំបន្តិច ។ ជាច្រើនរយដងណាស់មកហើយ លោកមេកន្ទ្រាញឯទៀតៗបានចូលមកកក់ដណ្តឹងទុក ។ ជាពិសេស កញ្ញាគីរី ត្រូវបានជាអនាគតកូនប្រសារលោកមេដំបន់ កោះញ៉ែក ជាក្លឺភឿនរបស់លោកមេមណ្ឌល ។

តែគេនៅរង់ចាំគ្រប់អាយុ ២០ឆ្នាំទើបរៀបការបានតាមប្រពៃណីស្រុកភ្នំយុកណាំល្បៀវ ។

រៀងរាល់ឆ្នាំ នៅទិវាចូលឆ្នាំថ្មី បណ្តាជនទូទៅក្នុងព្រៃភ្នំតាមតំបន់នានា គេតែងតែដឹកកូន ជញ្ជូនចៅ ទៅប្រជុំធ្វើបុណ្យ ងូតទឹកស្រង់ព្រះ ពូនភ្នំខ្សាច់នៅវត្តព្រៃកកម្ពី តាមប្រពៃណី ។

នៅទិវាដ៏មហោឡារិកនោះកូនក្រមុំ កូនកំឡោះ មន ស្មៀង ភ្នង ឥតប្រកែកប្រកាន់អ្វីទេ គេបេះផ្កា ស្លៀកពាក់តាមរបៀបស្រុកទេស ដើរប្រជ្រៀតគ្នាចូលក្នុងព្រះវិហារថ្វាយផ្កា ស្រង់ព្រះវារីដល់ព្រះពុទ្ធរូបធំមួយអង្គដ៏មានបារមីពូកែសក្តិសិទ្ធិ ដែលពួកភ្នំតែងគោរពបូជាទុកស្មើព្រះអាទិទេពរបស់គេជំនាន់បុរាណ ។

កញ្ញាមណ្ឌលគីរី ដូចមិត្តនារីរបស់នាងដែរ ឧបបាច់ផ្កាវំដួលក្រអូបឈ្ងុយ ប្រជ្រៀតចូលព្រះវិហារដ៏សែនចង្អៀតណែនណាន់តាន់តាប់ ។ រំពេចនោះឮ :

-យ៉ូយ ! យ៉ូយ ! ។ គីរីស្រែក ដោយបុរសកំឡោះម្នាក់ជាន់ជើងនាង ។

-សូមអភ័យទោសអ្នកនាង ខ្ញុំបានជាន់ដោយអចេតនា !

កំឡោះ សូផាន សុំទោសគីរី ។ កញ្ញាងើបមើលមុខបុរសដោយមានវាចា :

-លោក ! ខ្ញុំមិនប្រកាន់ទោសទេ ថ្ងៃបុណ្យ ជាន់បន្តិចបន្តួចប៉ុណ្ណេះ!

-អរគុណណាស់អ្នកនាង ! ។ សូផាន សំឡឹងភក្រ្តនារីឆ្មើមមិនដាក់ភ្នែកបេះដូងរន្ធត់ញ័រដោយត្រូវមន្តស្នេហ៍ ។

នាយនឹកសរសើរ :

-ឱ ! ព្រះជាម្ចាស់ ! នារីព្រៃភ្នំល្អម្ល៉ឹងៗធ្វើម្តេចបានធ្វើជាប្រពន្ធ ខ្ញុំនឹងបង្រៀននាងឱ្យតែងខ្លួនតាមម៉ូដខ្មែរនិយម នាំនាងអ៊ុតសក់លាបម្សៅក្រែម តើល្អស៊ីដាច់ក្រមុំទីក្រុងយ៉ាងណាទៅ ?

គិតរួច កំឡោះដើរជ្រៀតតាមក្រោយនារី ទៅដាក់ផ្កាទន្ទឹមនាង ថយមកអង្គុយថ្វាយបង្គំព្រះជិតគ្នា ចោលកែវភ្នែកដាក់គ្នាទៅវិញទៅមក ។

មណ្ឌលគីរី ចិត្តរំភើប ហឫទ័យញាប់ញ័រ ដោយមិនដែលបានឃើញប្រុសកំឡោះណាល្អស្អាតយ៉ាងសូផាននេះសោះ ។ ស្រស់ស្រីសំឡឹងគេមិនដាក់ភ្នែក មុខញញឹម រហូតដល់ក្ងួចកើតចិត្តបេតិស្នេហាប្រាថ្នាជាគូរួមរក្សអនាគត ។ នាងថយទៅឈរកៀនជញ្ជាំងគយគន់ប្រុសកំឡោះមិនឆ្អែតឆ្អន់ ធ្វើឱ្យមិត្តនារីរបស់នាងម្នាក់ដឹងសួរបញ្ឆោក :

-គីរី ! ម្តេចក៏សំឡឹងប្រុសកំឡោះនោះម្ល៉េះ ប្រហែល...ស្នេហាឬអ្វី ? រ៉ឺយមិនបានទេ ! កំឡោះនោះតាមគ្នាដឹងជាកូនកម្ពុជាយើងនៅផ្សារអូររាំង ? ជាកូនអ្នកជំនួញផងណា៎ !

-ពុទ្ធោ ! គេនៅអូររាំង ? ល្អណាស់លោកអើយយ៉ាមាណុបខ្វាន់ (ពាក្យស្ទៀងប្រែថា ល្អផុតមេឃ) ខ្ញុំស្រឡាញ់គេណាស់បងហារី ធ្វើម្តេចបានធ្វើប្តី?

-ហ៊ែះ ! កុំប្រាថ្នា កូនគេអ្នកផ្សារ មិនមែនស្រឡាញ់យើងកូនភ្នង ព្រៃភ្នំ ស្លៀកប៊ុងយ៉ាងនេះទេ កុំសង្ឃឹមអី គីរីអើយ !

កញ្ញាភ្នំយុកណាំលៀវ យកដៃវែតទ្រូងសំឡឹងហារី ។

-ហារី ! បើគេមិនស្រឡាញ់ខ្ញុំ ម្តេចក៏គេសំឡឹងមកម្ល៉េះ ? ឃើញទេគេសើចដាក់ហើយ លេបទឹកមាត់ក្អឹកៗ... ប្រហែលស្រឡាញ់មែនមិនដឹង ?

ហារី ធុញពេកសំឡក់ក្រឡែតដាក់គីរី ។

-អញស្អប់ណាស់ ស្រីក្រមុំអីស្រឡាញ់ប្រុសខុសទម្លាប់ស្រុកភ្នំ នៅមើលគេចុះ អញសុំលាឯងទៅមុនហើយ រកងូតទឹកព្រែកកម្ពី ។

-ឈប់ ! ឈប់ ! ឈប់ ! ចាំផងហារី... ។

ហារី ចេញបាត់ចោល នាងគីរី ឱ្យឈរម្នាក់ឯង ក្បែនវិហារ នាងចេញក្រៅ ទៅឈររកមើលជុំវិញវត្ត តែពុំប្រទះ ។ នាងឈរម្នាក់ឯងនៅក្រោមដើមគគីរ បៀមដៃមើលប្រុសស្នេហាដែលដើរមករកនាង។

-អ្នកនាង ! អ្នកនាង ! ម្តេចមិនមានវាចារកខ្ញុំ ស្អប់ខ្ញុំណាស់ឬ? បុត្រីលោកមណ្ឌលពុំព្រមនិយាយរកសូផានឡើយ ។ បុរសធ្វើជាងង៉ក់ដើរចេញ ។

-ឈប់ ! ឈប់ ! ឈប់ ! អ្នកកំឡោះ !។ គីរី ហៅ សូផានឱ្យឈប់ ។

-អ្នកនាងហៅខ្ញុំឈប់មានការអ្វី ?

-ចាំ ! ចាំ ! មានការទើបហៅ !

សូផាន ឃើញស្ថានការណ៍ល្អ ក៏ចូលជិតប្រលោមលួងលោម ។

-អូន ! អូនជាទេពអប្សរដួងចិត្តបង ម្តេចក៏នួនល្អងមិនមានវាចាឆាប់មក។ ឱភក្ត្រាដ៏ល្អផូរផង់ដូចចន្ទពេញវង់នេត្រាភ្លឺយង់ ចាំងឆ្លុះចូលមុតបេះដូងដ៏បរិសុទ្ធរបស់បង ម្តេចក៏មិនសាសងគ្រាន់តែញញឹម ?

នារីងើបមុខមើលបុរស តបសំដីដោយអៀនខ្មាស។

-បង ! បង ! ជាកូនអ្នកផ្សារអូររាំងឬអ្វី ? ម្តេចហ៊ានចាប់ទ្រចង្កាខ្ញុំលេងដូច្នេះ ? ប្រយ័ត្នគ្រួសារខ្ញុំឃើញ បងត្រូវបង់ជីវិតពុំខាន. . . ។

-អូន ! បងស្រឡាញ់អូនណាស់ បើស្លាប់ដោយរូបអូន បងពុំស្តាយជីវិតបន្តិចឡើយ.. អូន ! តើផ្ទះសម្បែង ឪពុកម្តាយនៅឯណា អូនឈ្មោះអ្វី ?

-កុំចង់ដឹងអ្វី នាំអោយមានគ្រោះថ្នាក់ទេ ស្គាល់តែឈ្មោះបាន ហើយ!

-ឈ្មោះអីអូន ?

-ចាំ! ឈ្មោះមណ្ឌលគីរី !

-មណ្ឌលគីរី ! មណ្ឌលគីរី ! យីឈ្មោះល្អណាស់ សមនឹងរូបអូនស្អាតឥតខ្ចោះ ! ផ្ទះនៅកន្លែងណា? អូន ! មេត្តាប្រាប់បងមក !

នៅភ្នំយុកណាំល្បៀរ ខាងជើងណាំបង ! ពុកអូនជាមេកន្ទ្រាញ. . . !

-លោកពុកជាមេកន្ទ្រាញផង ?

-ចាំ ! កុំចង់ដឹងច្រើនពេក ថាតើបងនៅអូររាំងមែនទេ ?

-បាទ ! បាទ ! ប្រាកដហើយអូន បងនៅផ្សារអូររាំង ម្តាយបងជាអ្នកជំនួញស្រូវ ឪពុកបងស្លាប់យូរហើយ !

-ហ៊ឺះ ! ហ៊ឺះ ! ឋានៈ វណ្ណៈ ពូជពង្សខុសគ្នាឆ្ងាយណាស់ កុំស្រឡាញ់ខ្ញុំធ្វើអ្វីនាំឱ្យតែមានគ្រោះថ្នាក់ណាំបង !

-ទេ ! ទេ ! ទោះបីមានមហាឧបសគ្គយ៉ាងណា បងតស៊ូស្លាប់រស់ជាមួយអូនហើយ...គីរីអើយ ! ជឿចិត្តបងចុះ បងស្រឡាញ់អូនលើសកែវភ្នែកបងទៀតណាអូន !

នារីសំឡឹងមុខបុរស ដោយសេចក្តីស្នេហាជ្រាលជ្រៅ សរព្រះកាមទេព បានមុជជ្រែកជ្រៀតចូលកប់កណ្តាលបេះដូង ស្រីបរិសុទ្ធមានប្រតិកម្មក្តៅកាយៗ ដោយឥទ្ធិពលស្នេហា។

-តោះបង ! នៅទីនេះពុំបានទេ ពួកគេសំឡឹងមកយើងច្រើនណាស់ មានរឿងរ៉ាវឥឡូវហើយ ពួកអាកំឡោះអស់នោះដៃដល់ណាស់ កាចព្រហើនទៀត !

-អូននាំបងទៅណាទៀត ?

-ចាំ ! ទៅមាត់ព្រែកកម្ពីមុជទឹកសប្បាយទាំងអស់គ្នា ហែលឱ្យឆ្ងាយពីគេនឹងបានជំនុំគ្នាទៀតមែនទេ ?

-ល្អណាស់គីរីអូន ! បងតាមអូនជានិច្ច មកអូនឡើងជិះសេះជាមួយបង !។ បុរសនឹងនារី បណ្តើរគ្នាទៅកាន់អាជានេយ្យ ដែលចងឱ្យស៊ីស្មៅក្រៅរបងវត្ត។ កំឡោះ ក្រមុំ ជិះសេះសាសងទៅរកមាត់ព្រែកដែលមានទឹកថ្លាដូចកញ្ចក់។ គេអង្គុយសាសងផ្តោះផ្តងពាក្យពេចន៍ស្នេហា។

-អូនគីរី ដើម្បីទុកជាអនុស្សាវរីយស្នេហាដំបូងរបស់បង ឱ្យសមតាមដួងចិត្តស្មោះស្ម័គ្ររបស់អូន បងសុំបំពាក់ចិញ្ចៀននេះជូនអូនហើយ ! តើកែវអូនយល់យ៉ាងណា ?

-ចិញ្ចៀន ? អា៎ ! បងបំពាក់ឱ្យខ្ញុំដោយស្មោះត្រង់មែនឬ ?

-បងហួសពីស្មោះហើយអូន !

អូនសុំបំពាក់ខ្សែអង្កាំភ្លុកនេះ ជូនបងដែរ បងថែរក្សាអង្កាំនេះជំនួសដួងចិត្តអូន ! បុរសទទួលខ្សែអង្កាំភ្លុកមកថើប គេចាប់ភក្ត្រគីរីថើប ស្រូបយកក្លិនបុប្ផជាតិព្រៃភ្នំ។

-កុំថើបច្រើនពេក ប្រយ័ត្នណាយក្រោយ !

-ទេ ! ទេ ! ល្អណាស់នេះគ្មានណាយទេអូន !

-ខ្ញុំមិនជឿទេចិត្តប្រុសស្រុកផ្សារដូចបង តែបានរូបឆោមនារីម្តងដោះដៃចោលឱ្យបុប្ផព្រៃភ្នំក្រៀមក្រំលុះមរណា !

-ទេ ! ទេ ! ឱ្យបងស្បថក៏បងហ៊ានដែរ !

-បងហ៊ានស្បថមែនឬ ?

-បងហ៊ានណាអូន !

បើអីចឹងទៅស្បថទាំងអស់គ្នា នៅចំពោះមុខព្រះក្នុងវិហារវត្ត គម្ពី !

-ទៅអូន ! បងស្រឡាញ់អូនហើយ !

គូស្នេហាខុសឋានៈ ខុសស្បែក គេក្រោកពីកន្លែង ដើរបេះផ្ការំដួលមួយបាច់ម្នាក់ ដើរចូលព្រះវិហារ ។ នៅចំពោះមុខព្រះភក្ត្រនៃព្រះពុទ្ធរូបមានឫទ្ធានុភាពបារមី គូស្នេហ៍ថ្វាយបង្គំ ថ្វាយកម្រងផ្កា អុជធូបទៀនហើយលើកដៃប្រណម្យមានវាចា :

"សូមព្រះចេស្តាបារមីដ៏លើសលុប ជួយចាំ ជួយឮជាសាក្សីនៃរូបខ្ញុំទាំងពីរនាក់ បានស្បថស្បែរថា ជាតិនេះមិនមានចិត្តបែកបែរប្រែចិត្តចោរគ្នាឡើយ, ខ្ញុំព្រះករុណាស៊ូស្លាប់ ស៊ូរស់ ស្មោះស្ម័គ្រតែមួយនឹងមួយ, ពុំមានគូណាជាពីរឡើយ, បើខ្ញុំព្រះករុណាភ្លេចពាក្យស្បថទៅរួមគូថ្មីទៀត សូមបារមីព្រះអង្គ វាយបំបាក់ករយើងខ្ញុំទាំង ២ នាក់ចុះ" ។

សូផាន ស្បថរួចបែរមុខញញឹមដាក់សង្សារ ។ គិរីញញឹមតប រួចលើកដៃប្រណម្យព្រះពុទ្ធរូប ។

" នាងខ្ញុំសូមលើកហត្ថសច្ចាប្រណិធាន ចំពោះព្រះភក្ត្រដ៏មានមហិទ្ធិរិទ្ធិ នាងខ្ញុំសូមសច្ចាថា មួយជីវិតនេះយកប្តីតែមួយគឺ សូផាន បើថ្ងៃមុខថ្ងៃក្រោយនាងខ្ញុំបែកបែរប្រែចិត្តមានប្រុសដទៃ សូមព្រះបារមីព្រះអង្គវាយប្រហារបំបាក់កនាងខ្ញុំចុះ...! " ។

គេស្បថរួច បណ្តើរគ្នាត្រសងចេញពីព្រះវិហារឆ្ពោះទៅពួកមនុស្សដែលធ្វើដំណើរកំសាន្តរកកន្លែងលេងល្បែងតាមប្រពៃណី ។ ក្រមុំ កំឡោះ ស្មៀង ភ្នង កួយ មន គេចូលរួមលេងល្បែងជាមួយគ្នាឥតប្រកាន់ស្បែក សាសន៍ អំបូរ ជាតិឡើយ ព្រោះក្នុងរដូវចូលឆ្នាំថ្មី តាមទំនៀមទម្លាប់គេមិនប្រកាន់ ។ ប្រុសស្រីក្មេងចាស់ អាចនិយាយទាក់ទងគ្នាបានតាមចិត្ត ។ ឯអ្នកតាបង់បត់ព្រៃភ្នំ ក៏បន្ធូរបន្ថយច្បាប់ជំនឿមិនកាច់ក ប្រកាន់ចាប់ទោសពៃរ៍អ្វីដែរ ។ តែបើក្រៅពីថ្ងៃបុណ្យខុសក្រៅផ្លូវការមិនបានជាដាច់ខាត មុខជាស្លាប់ចោលស្បែកឆ្អឹងពុំខាន ។ នេះជាជំនឿរបស់ពួកព្រៃភ្នំយុកណាំលៀវ ។ ទើបតែឃើញលើកនេះមានតែកញ្ញាមណ្ឌលម្នាក់ ហ៊ានប្រព្រឹត្តខុសប្រពៃណីច្បាប់ទម្លាប់ស្រុកភ្នំ ។

តើសេចក្តីស្នេហាដ៏បរិសុទ្ធរបស់គូកំសត់ មានជំហានបដិវត្តយ៉ាងណា ? បើខុសប្រពៃណីយ៉ាងនេះ ?

ពេលរសៀល កំណត់ព្រះសុរិយាគងខ្នងភ្នំនាទិសបស្ចិម ច្បាប់បញ្ញត្តឱ្យឈប់ទាក់ទងប្រុសស្រី វ៉ៃយក្រមុំ កំឡោះ ត្រូវកាត់ផ្តាច់ ។ គេបែកខ្ញែកគ្នាដោយអាឡោះអាល័យរៀង១ខ្លួន ។

ព្រះទិនករទាបទេរណាស់ហើយ សូផាន នឹង មណ្ឌលគិរី ដោយគោរពតាមច្បាប់បញ្ញត្តរបស់ម៉ែឪ គេសំឡឹងមុខគ្នាយ៉ាងយូរថយចេញបន្តិចម្តង១ ។

សូផាន ចាប់សេះជិះញាក់ខ្សែបំផាយចេញពីព្រៃកកម្ពី។ បុរសងាកក្រោយម្ដងៗ មើលមណ្ឌលគីរី ឈរបក់ដៃហៅល្ហើយៗ។

មនោម័យ ផាយយ៉ាងលឿនកាត់ពុះទ្រូងព្រៃនាំម្ចាស់វាទៅកាន់ស្រុកអូររាំង។

## ៣_ចិត្តបិតាស្នេហាចំពោះកូន

ពេលវេលាបានកន្លងទៅអស់រយៈជាងមួយសប្ដាហ៍ហើយ...។ នៅជើងភ្នំយុកណាំល្បៀវ រុក្ខានានាផ្លាស់ស្លឹក ផ្លែផ្កា ចោលក្លិនក្រអូបភាយៗ តាមជំនោរខ្យល់ត្រជាក់។ អ្នករស់នៅតាមព្រៃភ្នំចាប់ប្រកបរបរបាញ់សត្វ ទាក់ដីរ។ ពួកអ្នកកសិកម្ម ដាំសណ្ដែក ពោត ល្ង ស្រូវ ស្ពៃ...។

លោកមេកន្ទ្រាញ មណ្ឌល ក៏ចាប់ប្រកបការងារតាមមុខក្រសួង។ លោកមេមណ្ឌលជាអ្នកជំនួញខាងទិញភ្លុក កុយរមាស ស្បែកសត្វ ចង្កូម សត្វ ស្នែងខ្ទីង។ លោកបានចំណេញសន្ធឹកសន្ធាប់ លក់ឱ្យឈ្មួញខ្មែរកណ្ដាលដែលគេមកទិញដល់កន្លែង។

លោកមេកន្ទ្រាញ ស្រឡាញ់ថ្នាក់ថ្នមបុត្រីបណ្ដូលជីវិតលើសកែវភ្នែកលោកទៅទៀត មិនដែលជេរស្ដី ឬ បណ្ដោយឱ្យកូនស្រីធ្វើការអ្វីទេ។

ថ្ងៃមួយ លោកមេកោយដំបន់ភ្នំ ចេះតែនឹកឆ្ងល់ពីចិត្តកូនក្រមុំ ដែលមិនសូវនិយាយស្ដី អង្គុយព្រួយសញ្ជប់សញ្ជឹងគិតគូរយូរៗ លោកឃើញបុត្រីអង្គុយយំសម្រក់ទឹកភ្នែកហូររហាមហៀរលើថ្ពាល់។ បិតាចិត្តធម៌ ឃើញកូនព្រួយចំបែងដូច្នោះ លោករិះគិតនឹករកហេតុផលសព្វគ្រប់។ លោកនឹកថា កូនស្រីវ័យក្រមុំ ដល់អាយុពេញការរបៀននេះ មានការខឹងច្រើន រញ៉េរញ៉ៃវតាមធម្មជាតិបង្កើតមក ឬក៏កូនស្រីនេះព្រួយចិត្តឮិតស្រឡាញ់ប្រុសណាម្នាក់ ? លោកមណ្ឌល ហៅបុត្រីសម្លាញ់មកសួរបញ្ជាក់។

-គីរីកូនមាសឪពុក ! ពីពេលម្ដាយឯងស្លាប់ទៅ កូននៅជាមួយពុកគ្មានឡើយលំបាកអ្វីបន្តិចទេ។ ញ៉ាំស្រាប់ ឈ្នួលប្រុសស្រីមានបំរើ... កូនមិនដែលធ្វើការហាលក្ដៅ ហាលភ្លៀងម្ដងណាសោះ រហូតពេញក្រមុំ ពុកមិនដែលឃើញកូនមុខស្អុយ យំស្រែក ព្រួយកើតទុក្ខដូចពេលប៉ុន្មានថ្ងៃនេះទេ។ តើកូនមានរឿងអ្វីជាសម្ងាត់ក្នុងខ្លួន ប្រាប់ពុកមកកុំលាក់។ បើ ពុកអាចជួយដោះស្រាយបាន ពុកននឹងជួយឱ្យដល់ចំណុចចិត្តកូន។

កញ្ញាយកដៃជូតទឹកភ្នែកដ៏ថ្លារមៀលតក់ៗ លើថ្ពាល់យ៉ំសសិតធ្វើឱ្យលោកមណ្ឌលរឹតតែរន្ធត់ចិត្ត អាណិតបុត្រីខ្លោចចិត្ត ។ លោកបញ្ជាក់

-ម្ដេចគីរីកូនយំ មិនប្រាប់ពុកមក ?

-ចាំ ! ចាំ ! ពុករឿងនេះ ពុកអាណិតកូនកុំជជីកសួរច្រើនពេក កូនគ្មានរឿងអ្វីក្រៅពីស្នេហាទេ ពុកអើយ !

-សេចក្ដីស្នេហា ! ។ លោកមណ្ឌលភ្លាត់សំឡេង ?

- ចាំ ! ស្នេហា !

-កូនស្នេហាប្រុសឯណា ប្រាប់ពុកមក ?

-ពុក ! ខ្ញុំបានចាប់ចិត្តស្រឡាញ់ ស្មោះស្ម័គ្រលើបុរសរូបស្អាតម្នាក់ជួបគ្នាកាលចូលឆ្នាំថ្មីនេះ ។ កូនបានជួបគេនៅពេលចូលថ្វាយបង្គំព្រះក្នុងព្រះវិហារ ។ រូបគេល្អណាស់សមនឹងកូនរូបស្អាតដូចគ្នា ។ ប្រុសដែលកូនជាប់ចិត្តបេះមិនដាច់នោះ ជាកូនអ្នកជំនួញនៅអូររាំង ។ កូនបានជ្រុលខ្លួនលើគេស្បថស្បែរបានប្ដូរអនុស្សាវរីយទៅវិញទៅមក នេះពុកចិញ្ចៀនគេឱ្យកូន ។ ខ្ញុំក៏បានដោះខ្សែអង្គាំភ្លុកប្រគល់ឱ្យគេដែរ ។ កូនបានសន្យាថា មិនបំភ្លេចចោលគ្នាទេជាតិនេះ ។ ពុកមេត្តាកូនផងណាំពុក ! កុំប្រហារស៊ីសាច់កូនស្រីណាំ !

-ហ៊ឺ ! កូនស្រីមាសឪពុក ។ ពុកស្ដាប់សំដីកូនសែនវិយោគ ពុកអាណិតកូនណាស់ ប៉ុន្តែកូនស្ងួនឪពុកអើយ ឥតអំពើទេ សេចក្ដីស្នេហារបស់កូនត្រូវនិរាសហើយ ។ ពុកមានឋានៈជាមេកន្ទ្រាញ ត្រួតត្រាបណ្ដាជន ។ គេញញើតកោតខ្លាចពុកដូចខ្លា ។ គេទុកស្មើព្រះអាទិទេពរបស់គេ ។ ចុះបើពុកបណ្ដោយឱ្យកូនស្រីយកប្ដីមនុស្សក្រោមណ្ឌល ខុសញាតិសន្តាន ស្បែក ពណ៌យ៉ាងនេះ មុខជាជីវិតឪត្រូវវិនាសសាបសូន្យចោលកូនពុំខានឡើយ ។ កូនស្រីឪពុកអាណិតកិត្តិយស ពូជពង្សាវតារជាមេកន្ទ្រាញផង ។ កុំកូនបំបាក់មុខ បង្អាប់កេរ្តិ៍ឈ្មោះ ក្បត់ទំនៀមទម្លាប់ភ្នំឱ្យសោះណាំ !......ម្យ៉ាងទៀត ឪបានព្រមព្រៀងរៀបចំកូនឱ្យទៅកូនប្រុសលោកមេកន្ទ្រាញ កោះញឹកទៅហើយ ។ គេជាក្លើរបស់ឪផង !... បើកូនជជែសរឹងទទឹងនឹងច្បាប់ប្រពៃណី កូនសម្លាប់ឪពុកឱ្យហើយមក ចាំរត់ទៅរកប្ដីសម្លាញ់របស់កូន !

កញ្ញាឮឪពុកនិយាយដូច្នោះ ស្រែកយំងោងៗធ្វើឱ្យលោកមណ្ឌល អួលអាក់ចិត្ត ទប់ទឹកភ្នែកមេត្តាពុំបានដែរ ។

-ពុក ! កូនពុំយកប្រុសដទៃណាក្រៅពី សុផានរបស់កូនទេពុក ! ខ្ញុំស៊ូស្លាប់មុខពុក ទុកឱ្យពុកនៅសុខសាន្តថែរក្សាកូនឃុំរបស់ពុកចុះ ។ ខ្ញុំលាទៅ

រកសេចក្ដីស្លាប់ហើយ ។ ខ្ញុំមិនស្រឡាញ់កូនមេកន្ទ្រាញកោះញ៊ើកទេ មិនល្អសម នឹងរូបឆោមខ្ញុំបន្តិចឡើយ. . . ពុកអើយ. . . ហ៊ឺ ហ៊ឺ ហ៊ឺ. . .

-ព្រះជាម្ចាស់ៗ អ្នកតាព្រៃភ្នំ បាយ៉ាបប៊ីងបួមកផ្ដាច់យកជីវិតខ្ញុំទៅ ។ មិនចង់រស់នៅឃើញកូនស្រីយំចង់បានប្ដី យំសោកវេទនាស្រឡាញ់ប្រុសខុសជាតិសាសន៍.....អ្នកតាបង់បត់កាច់ខ្ញុំមកលោក !

ស្របពេលដែលលោកមេកន្ទ្រាញមណ្ឌល និងកូនក្រមុំយំនោះ អ្នកបំរើដើរចូលមកប្រកបដោយទឹកមុខមានការ ។

-ព្រះតេជព្រះគុណ ! លោកមេកន្ទ្រាញកោះញ៊ើកអញ្ជើញមក !

-អ្ហ៎ ! ភ្លើអញវាមកឬ ? អើឱ្យវាចូលមកចុះ ! ។

យ៉ាគេចេញទៅទទួលភ្ញៀវឱ្យចូលមក ។ ឯលោកមណ្ឌលខំធ្វើទឹកមុខរួសរាយ ។ លោកប្រាប់បុត្រីឱ្យស្លៀកពាក់ ឱ្យលែងយំស្រែកឱ្យរៀបចំទឹកមុខស្រួលបួលរង់ចាំទទួលឪពុកធមិ ។

លោកមេកន្ទ្រាញកោះញ៊ើកចូលមកដោយមានបណ្ណាការជាច្រើន នឹងកូនប្រុស ៥ នាក់ ហែហមពីក្រោយ ។ លោកមេកោយដំបន់កោះញ៊ើក ស្លៀកប៊ីងកំណាត់ក្រហម ជួតក្បាលសំពត់ខៀវ មុខគគ្រោតគគ្រាក ពាក់ខ្សែកភ្លុក ៥ខ្សែសក់ធ្លាក់ដល់ស្មា ។

-អៃយ៉ា ! អៃយ៉ា ! (សួស្ដី-សួស្ដី)

-សួស្ដីភ្លើ ! យើទៅណាមកណា មានឪទិនស្រាច្រើនផងអ៊ីយ !

-ហ៎ះ ! ហ៎ះ ! អញរលឹកឯងណាស់ បានជាមកណាំសម្លាញ់ ! ។ មេធំទាំងពីរឈប់ឱបគ្នាមួយស្របក់ ទើបចូលផ្ទះរោងដោលរបស់លោក មណ្ឌល ។

-អៃយ៉ា ! អៃយ៉ា ! លោកពុកធមិ !

-អើ ! កូនស្រីល្អណាស់អ៊ីយ អាចោរអន្តរធានហាំស្អាតបាតពេក ប៉ុន្តែមុខបែបមិនសូវស្រស់ទើយ ! ហ៎ះ ! ហ៎ះ !

ពួកបក្សបរិវារលោកមេកន្ទ្រាញកោះញ៊ើក សើចព្រមៗគ្នាព្រោចផ្កាឈើស្រស់ស្រីតាមទំនៀមប្រពៃណីឱ្យពរជ័យរបស់ពួកគេ ។

គីរីឮពាក្យលោក ចត្រា ជាឪពុកធមិនិយាយដូចនោះ នាងរញ្ជីវ ខ្ពាញ់ពន់ពេក ក្រោកចេញទៅប្រះដេកក្នុងបន្ទប់បាត់ទៅ ។

-មណ្ឌល ! ម៉េចកូនស្រីឯងមុខស្អុយម្ល៉េះ ?

-អត់ទោសទៅសម្លាញ់ កូនអញឈឺជាងមួយខែហើយ ទើបនឹងជាពីរបីថ្ងៃហ្នឹងណាំ !

-អូ ! នាងឈឺចង់បានប្តីទេដឹង ? នែ សម្លាញ់គ្នាមកលើកនេះប្រាថ្នាធំហើយ មកសុំភ្ជាប់ពាក្យសំដីដណ្តឹងកូនស្រីឯង. . . តើថាម្តេចទៀត ?

-អើ ! គ្នាបានសន្យាជាមួយរួចហើយតើ រឿងកូនចៅនៅតែដដែល ។ ចាំថ្ងៃក្រោយទៅ កូនគ្នាពុំទាន់ជាស្រួលបួល បើឯងមកចង់បានភ្លាមៗមិនកើតទេ ចាំសួរចិត្តសាមីខ្លួនគេសិន. . . !

-ម្តងមកថាអីចេះ ម្តងមកថាអីចុះ ពិបាកមែនអ្វីកូនស្រីវាមិនដែលធំជាងឪទេ ។ គ្នាមកម្តងៗយកស្រាទាំងចុងៗ សាច់ក្លែមទាំងអំរែកៗ.........

-អើ ! អញដឹងធុរៈឯងណាស់. . . ណ្តើយផឹកស្រាលេងទៅ.... ។

លោកមេកន្ទ្រាញមណ្ឌលឱ្យយ៉ា តេវាយស្គរប្រមូលកូនឃុំមកស៊ី ផឹករាំកំសាន្តក្នុងពិធីជប់លៀង ។

ទុង. . . ទុងៗៗ. . .

សូរស្គរឮពេញដំបន់ភ្នំ យុកណាំលៀវ ។

-វ៉ិយ ! វ៉ិយ ! កនយើង ! ចៅហ្វាយមានការប្រមូលហើយ លឿនៗប្រដាប់អាវុធគ្រប់ដៃ ! ។ នេះជាសំរែករបៀបអ្នកស្រុក ។ ៥ នាទី. . . ១០នាទី. . . បណ្តាកូនឃុំមកឈរកកកុញមុខផ្ទះ ។ ប្រដាប់ដោយ អាវុធ លំពែង ស្នា ធ្នូ ព្រួយ ខែល ។ ទៅតំរៀបគ្នាជាជួររង់ចាំទទួលបញ្ជាមេកន្ទ្រាញធំ ។

លោកមណ្ឌល ចេញមកប្រកាសមុខបណ្តាជន ដោយលោកមេកន្ទ្រាញកោះញ៉ើក ត្រូវជាក្លើរបស់អញ នឹងជាដន្លងទៅអនាគតរបស់យើងទៀតផង ។ ចូរអ្នកទាំងអស់គ្នា គោរពលោកដូចគោរពអញដែរ....!

-អេក្រូ ! អេក្រូ ! អេក្រូ ! (ជយោ ! ជយោ ! ជយោ !) ។ ពលរដ្ឋស្រែកព្រមៗគ្នា បន្លឺជ័យឃោសន៍ឱ្យពរដល់ចៅហ្វាយធំទាំង ២ ហើយស៊ីផឹករាំកំសាន្ត ទះសូរឮពេញដំបន់ភ្នំយុកណាំលៀវ ។

. . . . . . . . . . . . . . . . . . . . . . . . . . . . . . .

ការជប់លៀងបានប្រព្រឹត្តទៅក្នុងបរិយាកាសរាត្រីដ៏សែនសប្បាយរីករាយ ។ ព្រឹកស្អែកឡើង លោក ចត្រា មិត្តសម្លាញ់ទៅកាន់ដំបន់កោះញ៉ើក ។

# ៤-ចិត្តស្រីវ័យគ្រប់ការ

មួយសប្ដាហ៍កន្លងផុត... ។

-គិរី កូនមានរឿងអ្វីបានជាយំទាំងព្រលឹមយ៉ាងនេះ ។

-ចាំ ! ចាំ ! កូនសុំពុកទៅលេងទឹកឯស្ទឹងស្រឡាញ់ !

-គ្រាន់តែរឿនប៉ុណ្ណឹង កូនយំយែកដៃរ ពិបាកមែនកូនក្រមុំមួយ... ! ឈ្ហើយឈប់យំទៅ ចាំពុកទៅហៅកូនអ្នកស្រុកក្រមុំ ៥ នាក់ ឱ្យជូនទៅជាមួយ !

-ចាំ ! ចាំ ! កូនអរណាស់ពុក ! ?

កញ្ញាគិរី ចេញពីលោកមណ្ឌល ទៅរកបន្ទប់រៀបចំខោអាវ ស្បៀងអាហារ ។ លោកមណ្ឌល ទៅរកហៅកូនក្រមុំ អ្នកភូមិជិតដិតប្រាំនាក់ មកជូនបុត្រីគាត់ទៅកំសាន្ត ។

កញ្ញាព្រៃភ្នំប្រាំមួយរូបប្រដាប់ដោយស្បៀងអាហារ នឹងអាវុធ ការពារសត្រូវ ចេញដើរកាត់ព្រៃជ្រៅ សំដៅស្ទឹងស្រឡាញ់ដែលនៅឆ្ងាយជាង ៥ គីឡូម៉ែត្រ ពីភ្នំយុកណាំលៀវ ។

-អ្នកនាងសប្បាយចិត្តទេ ដើរកាត់ព្រៃជ្រៅលន្លង់លន្លោចយ៉ាងនេះ ?

- ចាំ ! សប្បាយណាស់បងសូភីអើយ ! បងចេះច្រៀងទេ?

- មិនចេះទេអ្នកនាង ! បើអ្នកនាងចេះច្រៀងមកឱ្យខ្ញុំសុំស្ដាប់ផង !

- មិនចេះទេ អៀនណាស់ខ្មាសសត្វបក្សាបក្សីក្នុងព្រៃ ... ។

- ដឹងខ្មាស់អីទេ សព្វបើច្រៀង !

- ចាស់ ! បើអីចឹង បងទាំងអស់គ្នាចាំជួយបន្ទរជាបទល្ខោនណា ខ្ញុំដើរតួនាងកែសុិន !

- ហះ ! ហះ ! ។ គេសើច១ព្រមគ្នា ទះដៃអោយគីរីច្រៀង ។

❮❮ អនិច្ចខ្លួនខ្ញុំជាស្រី ព្រាត់ប្រាស់ស្វាមីប្ដីសង្សារ គេទៅបាត់យូរ ទ្រូងអួលផ្សា ឱប្រុសស្នេហាមាសអូនអើយ ។ ខ្យល់បក់រំភើយផាត់ពពក ថ្ងៃណាបងមកទុក្ខអូនស្បើយ ឬមួយប្រុសបងភ្លេចអូនហើយ អូនយំខ្ទើយ១ រៀងរាល់ថ្ងៃ ។ ស្ដាប់សូរបក្សីបក្សា ហួចច្រៀងចរចារំពងព្រៃ តោរវៅយំឆ្លងសំឡេងរៃពីរោះពេកក្រៃរំជួលចិត្ត ❯❯ ។

ហះ ! ហះ ! ហះ ! ពីរោះណាស់អ្នកនាងអើយ ! ស្រណោកចង់តែបោកខ្លួន ឱ្យស្លាប់នឹងដុំតៅហ៊ូតែម្ដង ។ ទន់អស់ល្វែងក្រោមហើយអ្នកនាងអើយ ។

-ស្អប់ណាស់បង សូភី ជោរដល់ហើយ ខ្ញុំលែងច្រៀងឱ្យស្តាប់ !

-ខ្ញុំសរសើរទេតើអ្នកនាង ម្តេចក៏ឆាប់ងរខ្ញើតដូចសត្វខ្ជយម្ល៉េះ ?

ជីវិតទេពអប្សរទាំងប្រាំមួយ ដើរកាត់ព្រៃគ្រោក ព្រៃរបោះ ។ មិនយូរប៉ុន្មានទៅដល់ស្ទឹងស្រឡាញ់ ដែលហូរកង្កាញ់ត្របាញ់ទៅរកទន្លេ ។ ស្លឹកឈើលឿងទុំ ក្រហមជាំបណ្តែតវាសនាជាយឋាកម្មឱ្យរសាត់តាមខ្សែទឹក ទៅរកប្រភពទីដៅគ្មាន ។ វារីថ្លាដូចកញ្ចក់ថ្មី ចាំងឆ្លុះឃើញបាតដី ។ មច្ឆាតូចធំហែលរហង់ដេញកៀងគូឈ្មោលញី ។

កញ្ញាដងភ្នំទាំងប្រាំមួយ ផ្លាស់សំលៀកបំពាក់ទុកចុះ មុជហែលដេញប្រឡែងគ្នា ចាប់លេងកូនកាស លេងចាប់ដោះក្រមុំ លេងតូមតាក់ តាមល្បែងបុរាណសម្រាប់កំសាន្តក្នុងទឹក ។ គេដណ្តើមបានកូនកាស ឬគេតូមម្តង១គេដេញញៀវចញ្ចឹងត្រចៀករត់ពេញទឹក ។

ស្របនាទីនោះ បើអស់លោកអ្នកនាងរេចក្ខុទៅកណ្តាលព្រៃរំពៃគយគន់ទៅបុរសជិះសេះម្នាក់ ប្រកបដោយឬកក្លាហាន កំពុងបំផាយសេះត្រង់ត្រាប់ស្តាប់សំឡេងនារីក្នុងស្ទឹង ។ អ្នកជិះសេះរូបក្មេង ញាក់ទាញសេះឱ្យដើរតិច១ស្ទៀវមាត់ស្ទឹង ។ ភ្នែកគេរំពៃរកម្ចាស់សំឡេងហ៊ោសើច ។

អ្ហា ! ស្រី១ មកពីណាហែលទឹកល្អណាស់ លោកអើយ មណ្ឌល គិរីទេដឹង ? ។ បុរសលោតចុះពីខ្នងសេះយកជំនិះទៅចងលាក់ក្នុងគុម្ពោតព្រៃឆ្ងាយ ។ នាយដើរលប១ឃ្លាំមើងនារីទាំងប្រាំមួយ ។ នាយឃើញស្គាល់ច្បាស់ជាគូស្នេហា ក៏ឈរលើច្រាំងយកដៃអបបបូរមាត់ស្រែកហៅ ។

-អូនគិរី ! អូនគិរី ! អូនគិរី ! បងមកហើយអូន !. . . បុត្រីលោកមណ្ឌល ឮសំឡេង ក្រឡេកស្គាល់ច្បាស់ជាប្រុសសង្សារ ហែលកាត់ទឹក មុជសំដៅមករកប្រុសសង្សារដោយឆ្លើយតប ។

-បងសូផាន ! បងសូផាន ! បងសូផាន របស់អូន !

នារីទាំងប្រាំនាក់ ឈរមើលគិរីស្រឡាំងកាំង យកដៃរឹតពោះឈរមើលគូគេ ។ គូស្នេហាចិត្តតែមួយមកដល់ច្រាំង គេចាប់ឱបគ្នាថើបដោយសេចក្តីនឹករលឹកស្នេហាដ៏បរិសុទ្ធរកអ្វីប្រៀបឱ្យស្មើពុំបានឡើយ ។ នារីភ្លេចនឹកខ្មាសគូកនអស់ហើយ ។ នាងឱបរឹតថើបប្រុសស្នេហ៍ឥតឱ្យនាទីកន្លងទៅឥតប្រយោជន៍បានឡើយ ។

-អូន ! អូន ! បងរលឹក ស្រឡាញ់អូនណាស់ បងខំស្វែងរកអូន ជាង៥ថ្ងៃហើយ ឥតជួបសោះ ។ ថ្ងៃនេះសំណាងព្រេងបង ទេព្តានាំបងឱ្យមកជួបអូននៅទីនេះ ។ អូន ! អូនថើបឱ្យអស់ចិត្តចុះអូន !។

-ខ្ញុំរលឹកបងណាស់ដែរ អូនឈឺស្តមអស់ដោយរោគស្នេហា...! បងយកអូនទៅនៅជាមួយផងបានទេ ?

-អូនកុំព្រួយបងមកនេះ បំណងយកអូនទៅនៅជាមួយហើយ !

-សាធុ ! សាធុ ! អូនសប្បាយណាស់បើបងយកអូនទៅជាមួយ !

គូស្វ័ប្តូរជីវិត អង្គុយសំណេះសំណាលគ្នា ឱបរួមរក្សស្នេហាក្នុងព្រៃដ៏ស្ងាត់ ។ ឯចំណែកនារីទាំងប្រាំ ឃើញស្ថានការណ៍ពុំស្រួលរត់កាត់ព្រៃតម្រង់យកដំណឹងទៅជំរាបលោកមេកន្ទ្រាញមណ្ឌល ។ លោក មណ្ឌល កាលបើបានទទួលដំណឹងអកុសលភ្លាម ស្ទុះស្ទារទៅទូងស្គរប្រមូលកូនទ័ពឱ្យមកជួបជុំ ។ រំពេចនោះ ភ្នង ស្មៀង កួយ ជាជនចំណុះឃុំប្រដាប់ដោយ លំពែង ធ្នូ ព្រួយ ស្នា មកឈរចាំទទួលបញ្ជាការលោកធំ ។ លោកមេ កន្ទ្រាញ ស្រែកប្រកាសឱ្យកូនទ័ពស្តាប់ ។

-អ្នកទាំងអស់គ្នា រត់ឱ្យលឿន ទៅចាប់អាមនុស្សចោរកំណាច ដែលវាចាប់កូនក្រមុំខ្ញុំ នៅឯស្ទឹងស្រឡាញ់ ។ ចាប់ឱ្យបានយកមកឱ្យខ្ញុំសម្លាប់វាថ្វាយអ្នកតា ។ ប៉ុន្តែអ្នកទាំងអស់គ្នាមិនត្រូវវាយធ្វើបាបគេទេខុសផ្លូវច្បាប់ យកវាមកចងសួរចំឡើយ កាត់ទោសតាមញ្ញត្តិច្បាប់សិន ឮទេ ?

-បាទ ! បាទ ! បាទ ! ...

-រំពេចនោះ ទ័ពព្រៃភ្នំរត់ស្រ តម្រង់ទៅស្ទឹងស្រឡាញ់ចាប់ សូផាន ។

-បង ! បង ! នោះពួកគេមកចាប់ហើយ !

-យី ! អូនធ្វើម្តេចជួយបងផង !

-ស៊ូស្លាប់ទាំងអស់គ្នា !

កងកម្លាំងរបស់លោកមណ្ឌល បានចោមព័ទ្ធជុំវិញ សូផាន នឹងគីរី ដែលឈរប្រឱបទ្រូងគ្នាយ៉ាងក្លាហាន ។ គេលើកធ្នូដាក់ព្រួញតម្រង់សូផាន ដោយស្រែកហ៊ោកកញ្ជ្រៀវក្រេវៗ ។ គីរីស្រែកសន្ទាប់ទោសត្រូវរបស់នាង ។

-អ្នកទាំងអស់គ្នាមិនត្រូវសម្លាប់គេទេ ! មិនត្រូវសម្លាប់គេទេ ! សម្លាប់ខ្ញុំឯណោះវិញ ។

-ចូរពួកយើងចាប់ចងអាចោរ យកទៅជូនចៅហ្វាយយើងសម្លាប់ថ្វាយអ្នកតា ! ។

រំពេចនោះ ពេជ្ឈឃាដដៃដល់ ចូលចាប់សូផានចងស្លាបសេក បណ្តើរទៅភ្នំ យុកណាំល្បៀវ ។ ឯមណ្ឌលគីរី យំសោកបោកខ្លួនដូចសត្វអកញ្ញី ។ ពិធីហែរក្បួនបញ្ជូនអ្នកទោសស្នេហា នឹង គីរី បានប្រព្រឹត្តិទៅក្រោមបរិយាកាសដ៏សែនក្រៀមក្រំ ។ មិនយូរប៉ុន្មាន គេនាំជនកំសត់ដល់ជើងភ្នំ យកទៅចងឆ្កាងលើ

វេទិកាកាត់ទោសតាមច្បាប់របស់ស្រុកទេស។ ទាហាន ស្មៀង កួយ ភ្នង ឈរ រោមជុំវិញ ដោយមានអាវុធយុទ្ធភណ្ឌនៅដៃ តម្រង់ចំអ្នកទោសទារុណដែល ជាប់ឆ្នាំង។ គេនាំគ្នាហ៊ោក្រេវៗ សប្បាយ រង់ចាំលោកមណ្ឌលស្លៀកពាក់ប្រជុំ ចៅក្រម។

គីរីដឹងល្បិចកលសម្លាប់។ ថ្ងៃស្អែកបុណ្យឡើងអ្នកតាត្រូវយកមនុស្ស ទោសទៅខ្មៃប្រហារថ្វាយឱ្យអ្នកតាទត។ នាងគិតដូច្នោះរត់ទៅក្នុងបន្ទប់ យក ពុកមាត់ខ្លាមួយដៃទៅបង់គ្រប់ឌីទិនស្រា ដែលមាននៅក្នុងឃ្លាំងទាំងប៉ុន្មាន។ ដោយយល់ថាល្ងាចនេះស៊ីលៀងផឹកធំ ដើម្បីត្រេកអរសប្បាយនឹងបានមនុស្ស ទោស។ នារីបង់បំពុលស្រារួចចូលបន្ទប់យំខ្សឹកខ្សួលអាណិតប្រុសសម្លាញ់។

ភ្លាមនោះ លោក មណ្ឌល នឹងអ្នកមុខអ្នកការបានឈរប្រកាសខ្លាំងៗ ថា:

"ថ្ងៃស្អែកយើងត្រូវយកអាចោរថ្លើមខ្មៅនេះ ទៅសម្លាប់ថ្វាយអ្នកតា ចាស់ស្រុករបស់យើង។ វាក្លាហានណាស់ហ៊ានចាប់កូនក្រមុំយើងចែចង់។ អ្នក ទាំងអស់គ្នា ល្ងាចនេះដើម្បីតបស្នងសងគុណដល់អស់លោក ខ្ញុំសូមអញ្ជើញពល រដ្ឋទាំងអស់គ្នាមកប្រជុំផឹកស៊ី។ លោកកុំភ្លេចថា យើងមានស្រា ២០ ឌីទិនចុង ដែរ...សូមអញ្ជើញមកផឹកស៊ីកុំខាន ត្រូវរកដំរី បោប ឬ ងៀតឈ្លួសមកក្លែម ផង!"។

លោក មណ្ឌល ប្រកាសចប់ សំឡេងហ៊ោរកញ្ច្រៀងលាយនឹងសូរ ស្គរ វាយប្រកាសហៅកូនឃុំមកប្រជុំចាត់ចែងរកដំរីដុត រកឈ្លួសមកស៊ីផឹកយប់នេះ ។

រាត្រីបានយាងមកដល់។ ពលរដ្ឋប្រុសស្រីទាំងចាស់ក្មេងមូលមកប្រជុំ ស៊ីផឹករាំកំសាន្ត សប្បាយពេញបរិវេណភូមិ លោក មេកន្ទ្រាញ។ ពួកពេជ្ឈឃាដ ប្រដាប់ដោយអាវុធជាស្រេចប្រុងប្រៀបទុកប្រហារថ្ងៃស្អែក។ ការស៊ីសាច់ដំរី ផឹកស្រា បានប្រព្រឹត្តទៅក្នុងបរិយាកាសសែនមហាសប្បាយ។ ទាំងប្រុស ទាំង ស្រី រាំគ្រវីគូថជាងបទទ្វីស (Twist) ទៅទៀត។ គេរាំវែងខ្លួន Rock and Rool ជាងបីម៉ោងប្លាយប៉ុណ្ណោះ សភាពជ្រួលច្របល់កើតចលាចលដោយពុល ស្រវឹងស្រា ពួ តែក្អួតរ៉ែក ៗ ខ្លះថ្ងូរ ខ្លះដួល ដេកនទៀលពេញដី។ មើលទៅ លោក មណ្ឌល ទន់ខ្លួនដេកឥតបង្រះ។ កូនឃុំ ព្រមទាំងពួកពេជ្ឈឃាដ ដេក ហៀរកំអួតតាមមាត់។ ឯអ្នកទោសកំសត់ ត្រូវឈរឆ្កាងចុករោយស្រពន់។ នរៈ ខំបង្រះផ្តាច់ចំណង។ កញ្ញា មណ្ឌល គីរី ប្រដាប់ដោយកាំបិតរត់មកកាត់ចំណង ស្រាយឱ្យប្រុសស្នេហា។

-បងផាន រត់ទាំងអស់គ្នា!

-ទៅអូន ! ទៅតាមបងទាន់ពួកវាស្រវឹង !

-វាឥតស្រវឹងទេ អូនបំពុលថ្នាំដល់ពួកវាទេតើ !

-ល្អណាស់អូន ! រត់ចេញពីទីនេះភ្លាមទៅរកសេះបងដែលចងលាក់នៅស្ទឹងស្រឡាញ់ឯនោះ ។

គូស្នេហាទាំងទ្វេកាន់ដៃគ្នារត់ចេញ កាត់ព្រៃ កាត់វាលទៅរកអាជានេយ្យដែលគេចងលាក់ទុក ។ ដល់ភ្លាម កំឡោះលើកក្រមុំដាក់លើខ្នងសេះបំផាយយ៉ាងលឿនកាត់ព្រៃទៅកាន់អូររាំង ។

ចំណែកពួកភ្នំ យុកណាំល្បៀវ កាលបើស្វាងស្រា ស្បើយជាតិពុលហើយ ។ គេវាយស្គរហៅគ្នីគ្នាប្រកាសរឿងបាត់មនុស្សទោស ។ លោក មណ្ឌលឡើងពីសណ្ដំ ស្រែកហៅកូនចៅ ។

-ពួកយើងតាមរកអាចោរក្លាហាន វាចាប់យកបុត្រីយើងនាំទៅបាត់ហើយ ! ឃើញវាទីណាសម្លាប់វាចោលទៅ !

ពួកពេជ្ឈឃាដ កងកម្លាំងឃុំ កាន់អាវុធគ្រប់ដៃរត់ចូលព្រៃ ចែកផ្លូវស្ទាក់រកមនុស្សក្លាហាន ។

ប៉ុន្តែឥតប្រយោជន៍សោះ គូស្នេហាបានបំផាយសេះរាប់រយគីឡូ ចេញពីស្ទឹងស្រឡាញ់ទៅហើយ ។

## ៥_ទំនាស់វណ្ណៈគ្រោះថ្នាក់ជីវិត

-សូផាន បានស្រីនេះពីណាមក ស្បៀកពាក់មើលតែភ្នែងអីចឹង ? ជាម្ដេចនឹងឯង ?

មីងតៅ ជាម្ដាយសូផាន ។ ស្រីមាត់រឹងសំដីអាក្រក់ ចិត្តកាចឬស្យាឈរច្រត់ចង្កេះមើល សូផាន នឹងមណ្ឌលគិរី ដែលលុតជង្គង់ឱបជើងម្ដាយ សុំទោសដែលរូបគេបានស្រឡាញ់គ្នាជាប្ដីប្រពន្ធ ។ សូផាន អង្វរនឹងជំរាបម្ដាយដោយត្រង់ ។

-ម៉ាក់ ! ម៉ាក់ ! សូមអភ័យទោស ! នាងជាប្រពន្ធរបស់ខ្ញុំ ជាកូនលោក មេកន្ទ្រាញភ្នំ យុកណាំល្បៀវ ។ ខ្ញុំបានស្រឡាញ់នាងស្មើជីវិត ខ្ញុំបានស្បថស្បែរចំពោះព្រះភក្ត្រព្រះពុទ្ធរូបវត្តកម្ពីទៅហើយម៉ាក់អើយ !

-ហ៊ឺះ ! អញ់ក្តៅណាស់ អាសូផាន ឯងមិនត្រូវយកស្រីរបៀបនេះ ធ្វើប្រពន្ធទេ។ លែងវាចេញទៅ។ អញមិនឱ្យមីមនុស្សព្រៃមកធ្វើកូនប្រសាទេ។ អញបានដណ្ដឹងនាង ដារ៉ាន់ កូនអ្នកជំនួញនៅកំពង់ចាមឱ្យឯងរួចហើយ ចុះម្ដេចបានជាឯងយកស្រីភ្នងធ្វើប្រពន្ធ ?

-ទេ ! ទេ ! ម៉ាក់ ខ្ញុំមិនស្រឡាញ់ ដារ៉ាន់នោះទេ ខ្ញុំស៊ូស្លាប់រស់ជាមួយអូន គិរីប្រពន្ធខ្ញុំមួយនេះ !

-ឯងថ្លើមធំជាងអញ ជាម្ដាយទៅទៀតឬអ្វី ?

-ខ្ញុំមិនធំទេ តែខ្ញុំស្រឡាញ់នាងណា ត្រូវតែយកនាងនោះ។ ចំណែកដារ៉ាន់ ជាស្រីស៊ីវិល័យ ខ្ញុំមិនព្រមយកជាដាច់ខាត !

-អាសូផាន បើអាឯង នៅតែចចេសយកមីថោកដូចអាចម៍ធ្វើប្រពន្ធត្រូវចុះចេញពីផ្ទះអញៗកាត់កាលលែងរាប់ឯងជាកូន !

-តាមតែចិត្តម៉ាក់ចុះ បើម៉ាក់អាណិតកូន សូមប់កូនតាមម៉ាក់យល់ឃើញ។ ទោះបីគិរីជាស្រីថោកទាបដូចអាចម៍ បើខ្ញុំស្រឡាញ់ហើយ នាងក្លាយទៅជាមាស ជាពេជ្រ សម្រាប់សុភមង្គលរបស់ខ្ញុំណាំម៉ាក់ !

លោកអើយ ! ស្ដាប់ចុះ អាកូនអកតញ្ញូ វាបញ្ចេញសំដីអួតសរសើរមិលរមើសគុណខ្ញុំជាម្ដាយ ដែលចិញ្ចឹមវាពីតូចរហូតដល់ធំ វាក្លាយទៅជាសត្វក្រពើហើយតើ !

-ម៉ាក់ ! ម៉ាក់ ! បង្កើតកូនមក ត្រូវតែចិញ្ចឹមយ៉ាងនេះហើយ !។

មីងតៅ ក្ដៅដល់កំរិតធាក់ក្ដារតូង២ ផ្អើលអស់អ្នកជិតខាង។

-អាសូផាន ចេញពីផ្ទះអញឱ្យឆាប់ អាកូនក្រពើអញកាត់សាច់អាក្រក់មួយនេះចោល។ ចេញ២ពីផ្ទះអញឱ្យឆាប់២ !

អាសូរមណ្ឌលគិរីណាស់ នាងយំឱបជើងម្ដាយក្មេក។ ប៉ុន្តែម្ដាយឥតធម៌មេត្តាបានឱ្យរង្វាន់យ៉ាងខ្លោចផ្សា។

-ផាំង ! ផាំង ! ផាំង !អួយ...អុ អុ...។

អ្នកស្រីអតីតភរិយាលោក សៅរ៍ គាត់វាយកូនប្រសាទាត់ធាក់តាមកំហឹងចិត្ត។ មណ្ឌលគិរី នារីអភ័ព្វចុកដួលស្ទើរដាច់ដង្ហើម។

-អូន ! អូន ! ឈឺខ្លាំងណាស់។ បងរឹតទ្រូងឱ្យអូន។

សូផានរឹតទ្រូងឱ្យភរិយាដែលចុកបាត់មាត់។

-ប៉ាំង ! ប៉ាំង ! ប៉ាំង !។ មីងតៅ វាយសូផាននឹងឈើជ្រុងទល់បង្អួច។ ឈាមក្រហមហូរចេញពីក្បាលស្រោចលើអាវ។

-ម៉ាក់ សម្លាប់ខ្ញុំឱ្យហើយទៅ កុំទុក !

សូផាន ត្រកងភរិយាដួងចិត្តចុះដី ដាក់នាងឱ្យអង្គុយអ្នកឡើងទៅរៀបចំខោអាវនឹងសំពាយ ។

-អាសូផាន ! អារៀបចំខោអាវទៅណា ?

-ខ្ញុំទៅនៅស្រុកព្រៃហើយ នៅធ្វើអ្វីបើម៉ាក់កាចដូចយក្ស

-អាក្រពើ ទៅ ទៅ......ទៅឱ្យបាត់ពីមុខពីមាត់អញឆាប់ៗកុំនៅ !

-ខ្ញុំទៅឥឡូវហើយ ចាំរៀបខោអាវរបស់របរខ្ញុំសិន !

-សូផាន ប្រមូលខោអាវរួចយកចុះដី ចាប់សេះមកក្បែរនាង កញ្ញា សារឿន ជាប្អូនបង្កើត ឃើញបងរៀបដំណើរចេញ នារីស្ទុះឱបជើងបងប្រុសយំ ។

-បង ! បង ! កុំទៅណាចោលប្អូន ! ខ្ញុំស្រឡាញ់បងណាស់ ! ហ៊ឺ . . . ហ៊ុ . . . ហ៊ុ . . .

-ប្អូននៅជាមួយម៉ាក់ចុះ បងលាប្អូនទៅរកស៊ីស្រុកគេហើយ ។ កាលណាបងមានលំនៅជាក់លាក់ សឹមបងមកយកប្អូនទៅលេង ។

-បងស្រី ! បងស្រី ! នៅជាមួយខ្ញុំហើយ ខ្ញុំអង្វរម៉ាក់ ។

សារឿន ចាប់ឱបមណ្ឌលគីរីដោយពេញចិត្ត ។ គីរីយកដៃអង្អែលប្អូនថ្លៃដោយអាណិតរំជួលបេះដូង ។ នារី ឱបបងទាំងពីរយំក្តែងៗ ។ មីង តៅកាន់រំពាត់ផ្តៅចុះមកចាប់ដៃនាង សារឿនអូសចូលបន្ទប់ ។

-ទុកឱ្យវាទៅចុះ អាកូនថ្លើមក្រពើ វាចិត្តធំវាយកមីស្រើភ្នងធ្វើប្រពន្ធ វាល្អណាស់ហើយ ។

-ម៉ាក់ ! ម៉ាក់ កុំបណ្តេញបង ទុកឱ្យគាត់នៅជាមួយផងទៅប្រពន្ធបងល្អណាស់ម៉ាក់អើយ . . . ហ៊ុ . . . ហ៊ុ . . . ។

-មីសារឿន ភ្នែកងងឹងខ្វាក់ឬអ្វី បានជាមើលឃើញមីលំហៀវថា ល្អ ? ចូលក្នុងបន្ទប់ភ្លាមៗ ។

កញ្ញា សារឿន យំឮពេញបន្ទប់ ។ នាងខំអើតកតាមបង្អួចមើលបងប្រុសស្រីឡើងជិះសេះបំផាយចេញពីភូមិ ។

សេះបានបោលនាំម្ចាស់វាទាំង ២ នាក់កាត់វាលឆ្លងអូរ ចូលព្រៃ រកទីកំណត់គ្មាន ។

. . . . . . . . . . . . . . . . . . . . . . . . .

ជាងមួយសប្តាហ៍មកហើយ . . . សារឿនមានជម្ងឺជាទម្ងន់ ។ស្រស់ស្រីស្រែករវើរវាយ ទន្ទេញឈ្មោះ សូផាន ជាប់មាត់ ។ មីងតៅ ភិត

ភ័យជាកិយ្យោភាព រវៀសរវៃទទួលគ្រូមកព្យាបាល ។ ប៉ុន្តែអាការរោគនៅតែស្ថិតធ្ងន់ឡើង ៗ ។ ទើបខំត្រដរនិយាយលាយយំខ្សិកខ្សួលកាន់មាតា :

...ម៉ាក់... បើម៉ាក់ចង់ឱ្យ... ខ្ញុំរស់មានជីវិតតទៅ... សូមម៉ាក់ឈប់ខឹងនឹងបងផាន... ទៅហៅឱ្យបងមកនៅជាមួយកូន ។ ...បងផានអើយហ៊ិ ហ៊ិ អូនមុខជាស្លាប់ចោលបងហើយ...ម៉ាក់... ទៅហៅបងផានមកឱ្យខ្ញុំបានឃើញបងផានមួយភ្លែត ចាំកូនបិទភ្នែកស្លាប់ដោយស្រួល ... ។

មីងតៅឮបុត្រីពោលដូច្នោះ ចិត្តទោរទន់រលាយកំហឹងទឹកភ្នែកហៀរមួយរំពេច តបទៅកូនស្រីថា :

-សារឿន... កូនជាស្ងៀយឆាប់ឡើងចុះ ម៉ាក់នឹងរកគេទៅតាមរកបងប្រុសឯងឱ្យមកនៅជាមួយ ។ ម៉ាក់ឈប់ខឹង ឈប់ជេរប្រទេចវាទៀតហើយ ។

-ឱ្យគេទៅរកលឿន១មកម៉ាក់ ។ កម្លាំងខ្ញុំកាន់តែខ្សោយណាស់ហើយ បើរកពុំឃើញក្នុងរយៈពេលមួយអាទិត្យ...កូនខានឃើញមុខម៉ាក់...ខានឃើញបងផានទៀត ។

ដោយខ្លាចកូនស្លាប់ចោល មីងតៅអំពាវអស់បងប្អូនអ្នកស្រុកឱ្យជួយស្កាត់រកសូផានគ្រប់ដំបន់ គ្រប់ទីប្រជុំជន ឬ ទីជនបទ ។ រយៈជាងប្រាំថ្ងៃមកការរកសូផានបាត់សូន្យឈឹង ។ ចំណែកកញ្ញា សារឿន ជម្ងឺកាន់តែដុនដាបឡើង ។ នៅព្រឹកថ្ងៃទី ៦ នៃចុងសប្តាហ៍ ។ ស្រីអ្នកលក់បន្លែម្នាក់ បានជំរាបមីងតៅថា សូផានរស់នៅជាយក្រុងកំពង់ចាម រកស៊ីអូសទឹកលក់ ប្រពន្ធលក់បន្លែ មានកូនខ្ចមតូចមួយនៅមាត់ទន្លេ ។ បានទទួលដំណឹងភ្លាមមីងតៅនឹងស្រីអ្នកពាំពាក្យឡើងរថយន្តមួយរំពេចទៅរកសូផានឯក្រុងកំពង់ចាម ។ ស្រីទាំង ២ នាក់នឹកអរថា មុខជាបានជួបសូផានមិនខាន ប៉ុន្តែទៅដល់មាត់ទន្លេឃើញខ្ទមជរាទទេឥតម្ចាស់នៅ ។ មីងតៅរឹតតែក្តុកក្តួលចិត្ត ឈរសំឡឹងខ្ទមកំសត់ដែលមានតែឆ្នាំងដី ២ ចានថ្ម ៣ ប៉ុណ្ណោះ ។

ខណៈនោះមានតាចាស់ម្នាក់ ដែលមានជម្រកក្បែរនោះមកជំរាបមីងតៅថា :

-អ្នកស្រីរកក្មួយផានឬអ្វី... ផានមានរបួសជាទម្ងន់ណាស់ ឡានបុកបែកក្បាលសន្លប់ពេលអូសទឹកឆ្លងថ្នល់ ។ ឥឡូវទៅព្យាបាលនៅមន្ទីរពេទ្យកំពង់ចាម ។ ឯប្រពន្ធសូផានក៏នៅថែរក្សាប្តីឯពេទ្យដែរ... អូ ! អ្នកអើយ ប្រពន្ធរបស់ផានជាស្រីចិត្តល្អណាស់ ចេះថ្នមប្តីបំផុតហើយ ។

មីងតៅស្តាប់តាចាស់និយាយចប់ ស្រែកយំងោង ៗ :

-សូផានកូនម៉ាក់ ! កូនកាលនៅជាមួយម្តាយ មិនដែលធ្វើការអ្វីធ្ងន់ទេ។ ឥឡូវកូនអូសទឹកលក់... ព្រោះតែម្តាយ...ម៉ែខុសហើយកូនអើយ ! ម៉ែមកយកឯងទៅវិញ មិនឱ្យលំបាកទៀតទេ។

រំពេចនោះ ស្រីទាំងពីរនាក់លាតាចាស់ទៅកាន់មន្ទីរពេទ្យជាបន្ទាន់។

លោកគ្រូពេទ្យបាននាំមីងមេម៉ាយទៅបង្ហាញបន្ទប់។ កាលបើក្រឡេកឃើញសូផានរុំសំពត់ស ពេញក្បាល ពេញខ្លួន ដែលមានគីរីអង្គុយបក់ផ្លិតបំរើចុងជើងនោះ មីងមេម៉ាយយំឱបកូនប្រុស។

-សូផាន កូន ! សូផាន ម្តេចកូនមានគ្រោះថ្នាក់យ៉ាងនេះ កូន ! កូននិយាយរកម៉ាក់មក... ម្តេចនៅស្ងៀមយ៉ាងនេះ។

សូផានប្រែខ្លួនបានតិចៗសំឡឹងម្តាយ ទឹកភ្នែកហូរចេញមក។ នាងគីរីជំរាបម្តាយក្មេក។

-អ្នកម៉ែ... បងរបួសធ្ងន់ណាស់ ពុំអាចនិយាយបានទេ គ្រាន់តែដឹងខ្លួន នឹងកំរើកបានប៉ុណ្ណោះ។

-ពុទ្ធោ ! កូនម៉ាក់មានកម្មអ្វីម្ល៉េះ ! លោកអើយ នេះមកតែពីរូបខ្ញុំជាម្តាយ។ សូផាន ... សូផាន ម៉ែមកយកឯងនឹងប្រពន្ធឯងឱ្យទៅនៅជាមួយវិញហើយ កូនកុំខឹងអ្វីនឹងម៉ែ... ។

-ជនអភ័ព្វខំលេបទឹកមាត់រួចនិយាយខ្សាវៗ យ៉ាងហត់។

-ម៉ាក់... ម្តេចដឹងខ្ញុំនៅទីនេះ ឯណាប្អូនស្រីខ្ញុំ សារឿន នៅឯណា ...សារឿន... សារឿន បងរលឹកអូនណាស់។

មីងតៅ យកដៃអង្អែលកូន ដោយទឹកភ្នែកហូរជោកថ្ពាល់មិនដឹងខ្លួន ។

-សូផាន ! សូផាន ! សារឿនប្អូនរបស់ឯងឈឺធ្ងន់ណាស់ សារឿន ឱ្យម្តាយមកតាមយកកូនទៅនៅវិញ ទើបបានជា។

-ម៉ែ... ទៅថែប្អូនសិនចុះ ...ខ្ញុំមានប្រពន្ធមានគ្រូពេទ្យថែរក្សាហើយ ម៉ែទៅប្រាប់សារឿនថា ខ្ញុំសុខចិត្តទៅវិញឱ្យប្អូនខំញ៉ាំបាយ ខំផឹកថ្នាំឱ្យជាឆាប់ៗ នឹងអាលមកយកខ្ញុំទៅផង។

..........................

នាងសារឿន បានដឹងថាបងប្រុសមានរបួសជាទម្ងន់ នាងយំអាណិតបងរហូតអត់បាយ អត់ទឹក។

-សារឿន កូនមាសម្ដាយឈប់យំណាកូន ! សូផាន វាមកនៅឆាប់ៗនេះហើយ ។ វាផ្ដាំមកឱ្យកូនខំញាំបាយច្រើនៗឱ្យឆាប់ជានឹងអាលទៅទទួលយកវាមកនៅជាមួយ. . . ។

. . . . . . . . . . . . . . . . . . . . . . . . . . . . . .

មួយអាទិត្យកន្លងផុតទៅ គ្រួសារមីងតៅបានមករស់នៅជួមជុំគ្នាដូចដើមវិញ ។

កញ្ញា សារឿន នឹង មណ្ឌលគីរី ស្រឡាញ់បងប្អូនចាក់ទឹកមិនលេច ។

រាល់ៗល្ងាច គេសង្កេតឃើញ សូផាន សារឿន មណ្ឌលគីរីនាំគ្នាដើរលេងសប្បាយ ។ មណ្ឌលគីរី ជាស្រីមេផ្ទះដ៏ពេញចំណាប់ ។ ធ្វើការបំរើម្ដាយក្មេក បំរើប្ដីមិនទុកដៃឱ្យទំនេរទេ ។ សារឿន ពេញចិត្តនឹងបងថ្លៃណាស់ ដែលជានារីម្នាក់កម្ររកបានក្នុងលោក ។

## ៦_ចិត្តម្ដាយឬស្យា សង្សារកើតទុក្ខ

មួយខែកន្លងមក. . . សូផានបានចូលធ្វើការជាយន្តការីនៅរោងចក្រឯកជននៅក្រុងកំពង់ចាម ។ រៀងរាល់ទិវារាត្រី មាណពនឹកមមៃដល់ភរិយាឧត្តមស្នេហា មិនដឹងនាងព្រួយលំបាកយ៉ាងណា រស់នៅជាមួយគ្រួសារ ។ នាយព្រួយបារម្ភជានិច្ចចំពោះចិត្តកាចសាហាវរបស់ម្ដាយអ្នកមិនពេញចិត្តនឹងកូនប្រសាដែលមានជាតិសាសន៍ វណ្ណៈ ខុសគ្នាដូចមេឃ នឹង ស្មៅ ។

មែន ! បើអស់លោកអ្នកនាង រេចក្ខុទៅមើលគ្រួសារមីងតៅម្ដង តើមានប្រតិកម្មយ៉ាងណាខ្លះ ?

-នែ ! នាងស្រីល្អ ផ្លាស់សំពត់អាវថ្មីៗចេញ នាងឯងស្លៀកពាក់សំពត់អាវរហែកៗនេះបានសមរឹក ។ ក្រែងនៅព្រៃភ្នំស្លៀកតែស្លឹកឈើ វីណ្ឌ កន្ទបទេតើ !

មីងតៅចាប់សម្រាតសំពត់ខ្មៅពីចង្កេះគីរីចេញ បោះសំពត់រហែករាប់រយបំណាស់ឱ្យមណ្ឌលគីរីស្លៀក ។ ស្រីអភ័ព្វក៏ធ្វើតាមបញ្ជាម្ដាយក្មេកចិត្តកាចឬស្យា ។

-ម៉ែឱ្យខ្ញុំធ្វើការអ្វីទៀត ស្រូវមួយជង្រុកខ្ញុំកើបច្រកបាវអស់ហើយ!

-អើ ! បើអស់ហើយជ្រះទឹកសិនទៅ នឹងអាលរែកទឹកចាក់ឱ្យពេញពាងទាំង ១៥ កុំខាន តែរែកមិនពេញអញវាយបំបែកក្បាល !

-ចាំ ! ចាំ ! ខ្ញុំអស់កម្លាំងណាស់ សុំសម្រាកមួយស្របក់សិន !

-ទេ ! ទេ ! គ្មានសម្រាកអ្វីទេ មកនៅផ្ទះអញត្រូវតែធ្វើការគ្មានសម្រាក បើពុំសុខចិត្តទៅស្រុកភ្នំនាងឯងវិញទៅ !

មណ្ឌលគីរី ដោយស្រឡាញ់ប្តីងប់ងល់ពេក នាងដើរទៅខាងក្រោយផ្ទះយកប៉ោតរែកទឹកអណ្តូង ដែលនៅឆ្ងាយពីផ្ទះជាងមួយគីឡូម៉ែត្រ ។ នាងរែកបណ្តើរ យំបណ្តើរតាមផ្លូវ ។ កម្លាំងនាងអន់ថយជាលំដាប់ ។ នារី នឹកឃើញសព្វគ្រប់កាលនៅជាមួយបិតាមិនដែលធ្វើការអ្វីធ្ងន់ ឬត្រូវថ្ងៃក្តៅខ្លោចស្បែកដូច្នេះឡើយ ។ ឥឡូវខ្លួននាងមានកម្មត្រូវទទួលទណ្ឌកម្មពីធម្មជាតិអាក្រក់គ្រប់ជំហាន ។

កាលបើរែកទឹកចាក់ពេញពាងហើយ នាងអស់កម្លាំងពេកចូលទៅដេកសម្រាកក្នុងបន្ទប់ដោយស្ងៀមស្ងាត់ ។ ដោយការល្វើយអស់កម្លាំងស្រីអភ័ព្វបិទភ្នែកគេងលក់ទាំងជលនេត្ររហាម ។ ឯព្រះសុរិយា ក៏បានរំកិលព្រះកាយខិតជិតរូងបព្វតានាទិសបស្ចិម ។ មីងតៅ ដែលដេកចាំតែបរិភោគស្រាប់នោះចាំបាត់ៗពុំឃើញ គីរី លើកម្ហូបអាហារមកក៏ឆ្ងល់ខ្លាំង ដើរទៅរកបន្ទប់នាង ។ គាត់ថយក្រោយភ្លាមទៅកាត់រំពាត់ផ្តៅប៉ុនមេដៃមកកាន់ ស្ទុះចូលទៅក្នុងបន្ទប់ ។

-ខ្វាប់ ៗ ខ្វាប់ ៗ ខ្វាប់ ! ៗ

-អូយៗ អូយ ម៉ែអភ័យទោសកុំវ៉ាយខ្ញុំ ខ្ញុំឈឺណាស់ !

នារីយំឱបជើងមីងតៅ ។ ឯស្រីកំណាចគ្មានត្រាប្រណីទេ វាយកូនប្រសាដូចវាយត្រី ។

-មេសត្វតិរច្ឆានថ្ងៃនេះហើយ វាដេកភ្លេចដាំបាយទឹកអស់ ធ្វើការបន្តិចបន្តួចវាហត់ វាថ្ងូរ. . . វាធ្វើដូចហត់ណាស់ !

-អូយ ! អូយ ! ម៉ែអើយឈឺណាស់ ខ្ញុំរាងហើយ !

ស្រីកំណាចវាយវាត់ផ្តៅពេញកាយស្រី ក្រហមពេញប្រាណ ជាំឈាម ។ នារីទុគិតខាំមាត់ សង្កត់ធ្មេញទទួលទណ្ឌកម្មយ៉ាងមហាទារុណ ។

-ទៅ ! ទៅ ! រកដាំបាយឱ្យលឿនៗ ។

-ចាំ ! ចាំ ! ឈប់វាយខ្ញុំទៅម៉ែ ខ្ញុំទៅដាំបាយ !

នារីដើរចូលទៅក្នុងបន្ទប់បាយរកឆ្នាំងច្រកអង្ករ ។ នាងដណ្តាំបាយបណ្តើរយំសសិតខ្សឹកខ្សួលបណ្តើរ ។ កញ្ញា សារឿន ដែលទើបត្រឡប់ពីស្រុកស្រែ ផ្លាស់សំលៀកបំពាក់ទុករត់រកបងស្រី ។ នាងឮសំណោកក្តុកក្តួលក្នុងផ្ទះបាយ ។

-បង ! បង ! នរណាធ្វើអីបង បងយំយ៉ាងហ្នឹង ?

-អូយ ! អូនកុំពាល់បងខ្លាំងពេក បងឈឺក្រហាយរោលរាលពេញខ្លួនអស់ ! សារឿន ដោះអាវបងថ្លៃមើលឃើញឈាមក្រហម ឃើញស្នាមរំពាត់ជាំខ្មៅ នាងឱបថើបបងស្រីយំទាំងពីរនាក់ ។

-បង ! ម៉ែវាយបងច្រើនណាស់ទៅឬអីបង ! ខ្ញុំពុំចង់ទៅណាចោលបងទេ តែទៅម៉ែវាយធ្វើបាបបង ហ៊ឺ...ហ៊ឺ... បងឈប់ដាំបាយទៅសម្រាន្តចុះទុកឱ្យអូនធ្វើជួស !

-មិនបានទេអូន ! ម៉ែវាយបងទៀតឥឡូវ !

-ទេ ! ទេ ! ទុកឱ្យម៉ែវាយខ្ញុំចុះ !

-កុំអី ទុកឱ្យបងទ្រាំតាមកម្មរបស់បង !

ស្របពេលដែលនារីទាំងពីរយំឱបគ្នាក្នុងផ្ទះបាយ មីងតៅមកទាន់ ។

-នែ ! មីសារឿន ម៉ែង៉ែងឬបានជាមកយំឱបគ្នាយ៉ាងហ្នឹង !

-ចាំ ! ទេម៉ែ ! ម៉ែវាយបងចេញឈាមរបកស្បែកអស់ ចុះបងឈឺយ៉ាងណា ? ត្រង់រូបម៉ែគ្រាន់តែបន្លាមុត ឬដើរជំពប់ជើងបន្តិចបន្តួច ម៉ែថ្ងូរថាឈឺ ចុះបើវាយគេដូចសត្វតើគេឈឺយ៉ាងណា ?

-មីសារឿន ! ង៉ែងចង់ធ្វើម្ដាយអញឬ ? ចេញឱ្យឆាប់ៗ សារឿនមិនព្រមចេញ ស្ទុះឱបជើងបងថ្លៃយំ ។

-ខ្វាប់ ៗ ខ្វាប់ ប៉ាំង ! ៗ... ។ មីងតៅវាយ កញ្ញាទាំងពីរនាក់ ។ មណ្ឌល គីរី ឃើញប្អូនស្រីត្រូវរំពាត់ នាងស្ទុះក្រាបលន់តួម្ដាយក្មេក ។

-ម៉ែ ! ម៉ែ វាយខ្ញុំនេះវិញ ខ្ញុំទេតើដែលខុស !

ថារួចស្រស់ស្រីចូលរងរំពាត់ជួសសារឿន ប៉ុន្តែ សារឿនមិនព្រម នាងយកខ្នងការពារជួសបងស្រី ។

មេផ្ទះកំណាចដូចរន្ទះបាញ់ កាលបើវាយបុត្រីទាំង ២ រួចក៏ចូលកាន់គ្រែដេកយកកម្លាំងសណ្ដំពិសតទៅទៀត ។

មណ្ឌលគីរី នឹង សារឿន នៅឱបគ្នាយំពេញបន្ទប់ដោយឈឺក្ដៅពេញប្រាណ ។

-កុប ! កុប ! កុប ! ។ សូរជើងសេះមកដល់ ។

សារឿន ស្ទុះចេញទៅក្រៅមើល ។

-បង ! បង ! បង សូផាន ! បង សូផាន !

សារឿន ឱបចង្កេះបងប្រុសយំ ។ មណ្ឌលគីរី ស្ទុះតោងចង្កេះប្ដី ។

-អូន ! អូន ! នរណាធ្វើអីអូន បានជាអូនយំទាំង២ នាក់ ?

-ហ៊ី ! ហ៊ី ! បងអើយ... ម៉ាក់វាយស្រីបែកឈាមពេញខ្នងអស់ហើយ !

-ពុទ្ធោ ! ម៉ាក់វាយអូនគីរី ?

បុរសស្ទុះឱបបណ្ដូលជីវិត ដោះអាវមើលឃើញស្នាមរំពាត់កន្ទួលចេញឈាម។

-អូនគីរីមាសបង ! អូនឈឺយ៉ាងណា អូនខ្លោចផ្សាយ៉ាងណាដែរ អូន ! ប្រាប់បងមកអូន បងរកថ្នាំ រកស្លឹកចេកស្ងំឱ្យអូន !។

បុរសអភ័ព្វនិយាយ ដៃអង្អែលកាយស្រីសង្សារថ្នម១ ទឹកភ្នែកមេត្តាករុណា អាណិតប្រពន្ធហូរឈាមធ្លាក់លើទ្រូង។

-មិនឈឺទេបងប៉ុណ្ណេះ សូមឱ្យតែចិត្តបងស្មោះត្រង់លើរូបអូន !។

-អូននៅសង្ស័យអ្វីទៀត បងស្រឡាញ់អូនស្មោះអស់ពីពោះទៅហើយ...បងស្រឡាញ់អូនរកអ្វីប្រៀបប្រដូចគ្មានឡើយ !

-អូន ! អូនកុំយំ ! បងស្រឡាញ់អូនណាស់ !។

ខណៈដែលបុរសគួលលកញ្ជីឈ្មោលថ្នាក់ថ្នមបីបមលួងគ្នានោះ ស្រីកំណាចឬស្សាឈរស្ដាប់នៅក្រៅជញ្ជាំង។ មុខឡើងក្រហមកាន់រំពាត់ចូលក្នុងបន្ទប់។ គាត់លើកដំបងសំពងក្បាលមណ្ឌលគីរី នឹង សូផាន។

-អាសូផាន ! អាឯងមិនត្រូវឱបក្រសោបមេស្រីចង្រៃនេះទៀតទេ ! មើលឯងតាមអញជាម្ដាយ ឬ តាមប្រពន្ធថាមកឱ្យឆាប់១ អញនឹងអាលចាត់ការទៅទៀត ?

-ម៉ាក់ ! ម៉ាក់ ! អាណិតទ្រូងកូនទៅ កូនស្រឡាញ់ មណ្ឌលគីរីណាស់ !

-អា្ហ ! ឯងស្រឡាញ់វាជាងម្ដាយទៅទៀត ?

ប៉ាំង ! ប៉ាំង ! ប៉ាំង ! ...។ ម្ដាយចិត្តក្ដៅវាយសំពង សូផាន។ មណ្ឌលគីរីឃើញដូច្នេះយកខ្លួននាងរងមុខដំបង។

-ប៉ាំង ! ប៉ាំង ! ប៉ាំង ! ។

-ង៉ែងពូកែ ឬ សំពងង៉ែងឱ្យងាប់ ! ។

-ម៉ាក់ ! ម៉ាក់ ! ឈប់ ឈប់ កុំវាយគេ ខ្ញុំតាមម៉ាក់ហើយ !

-ឯងតាមអញមែនឬ ?

-បាទ ! បាទ ! ។

-អើបើតាមអញត្រូវងូតទឹកឱ្យជ្រះ ស្លៀកពាក់ឱ្យស្អាត ឡើងរថយន្តទៅក្រចេះជាមួយអញ។

-ទៅធ្វើអ្វីម៉ាក់ !

-អញនាំឯងឱ្យទៅមើលកូនក្រមុំគេ ដែលអញបានស្ដីដណ្ដឹងទុកយូរហើយនោះណា៎ !

-ពុទ្ធោ ! បានសេចក្ដីថាម៉ាក់សម្លាប់ជីវិតស្រីកំសត់ម្នាក់ឱ្យស្លាប់ទៅហើយឬអ្វី ?

-អើ ! អញមិនឱ្យអាឯងយកមេស្រីព្រៃភ្នំ ដូចសត្វពន្លាត់នេះទៀតទេ ត្រូវលែងវាចោលទៅ ?

បុរសឈ្មោកមុខ យំខ្សឹកខ្សួលសម្លឹងមុខប្រពន្ធ ដែលឈរយំក្បែរនោះ ។

-អូន ! អូន ! គិរីអើយ យើងបែកគ្នាហើយជាតិនេះ បងត្រូវម្ដាយបង្ខំឱ្យយកប្រពន្ធថ្មី. . . តែទោះបីយ៉ាងណា បងពុំចោលអូនទេ បងត្រូវបំពេញចិត្តម្ដាយរបស់បងមួយគ្រាសិន ! ។

គូស្វាមីភរិយា យំឱបរឹតទ្រូងគ្នាសែនវេទនាភ្នែក ។

រំពេចនោះ មីងតៅស្លៀកពាក់ ចាប់ទាញដៃ សូផាន ឱ្យចេញពីមណ្ឌលគិរី ទៅរករថយន្តដែលឈប់មុខគេហស្ថាន ។

មណ្ឌលគិរី នារីរងកម្ម យំសស្រាក់តតជាប់ទឹកភ្នែកជាមួយ សារឿន :

-សារឿនអូន ! បងពុំអាចរស់នៅជាមួយអូនបានទៀតទេ បងនឹងវិលទៅរស់នៅជាមួយឪពុកបងវិញ . . . បង បងលាអូនក្នុងថ្ងៃនេះហើយ . . . ទុកឱ្យបង សូផានរស់សុខសាន្តជាមួយប្រពន្ធក្រោយចុះ ។

-ទេ ! ទេ ! បងខ្ញុំទៅតាមបងដែរ ខ្ញុំមិនអាចរស់នៅដោយខ្វះរូបបងទេ !

-កុំអូនសារឿន ទៅមិនបានទេស្រុកបងឆ្ងាយណាស់ !

-ទោះបីឆ្ងាយយ៉ាងណាក៏ដោយ ក៏អូនសុខចិត្តដូចបងទៅដែរឱ្យស្គាល់កន្លែងរបស់បង !

-ទៅមិនកើតទេអូន ! ទុកឱ្យបងដើរកាត់ព្រៃផ្សៃម្នាក់ឯងបានហើយ !

-ទេ ! ខ្ញុំទៅជាមួយបងហើយ ! កុំឃាត់ខ្ញុំមិននៅទេ !

និយាយចប់ មណ្ឌលគិរី រៀបចំខ្លួនប្រាណចុះដី លាប្អូនស្រី ។

-អូនកុំទៅ ! បងលាហើយ ! ។ នាងយំអាឡោះអាល័យប្ដីអាល័យប្អូនថ្លៃ ។

មណ្ឌលគិរីឱបបង្វេចខោអាវ ដើរកាត់ព្រៃទៅរកភ្នំយុកណាំល្មៀវ ដែលនៅសែនឆ្ងាយរាប់រយយោជន៍ ។ នាងដើរងាកក្រោយម្តងៗ មើលមកលំនៅស្វាមី ។ ស្រស់ស្រីអភ័ព្វដើរបានប្រហែល ៥ គីឡូម៉ែត្រស្រាប់តែឮស្នូរជើងសេះតាមពីក្រោយ ។

-បងគិរី ! បងគិរីចាំអូនផង អូនទៅនៅជាមួយបងដែរ ! បងគិរី ! បងគិរី !

នាងឈប់ ! យកដៃជូតទឹកភ្នែកសំឡឹងប្អូន

-វិលវិញទៅអូន កុំតាមបង ! ៗ

-ខ្ញុំទៅជាមួយបងហើយ កុំឃាត់ ។ ឡើងជិះសេះមកបង ! មណ្ឌលគិរី នឹង សារឿន ឡើងជិះសេះទាំងពីរនាក់បំផាយយ៉ាងលឿនទៅភ្នំយុកណាំល្មៀវ ។

. . . . . . . . . . . . . . . . . . . . . . . . . . . .

ការធ្វើដំណើរកាត់ព្រៃជ្រៅ ស៊ីពេលវេលាអស់មួយយប់គត់ ។ នារីក្លាហានទាំង ២ នាក់ ឥតបានដេកសម្រាកមួយនាទីឡើយ ។ រីឯអាជានេយ្យក៏លុនគ្មានសំចៃកំឡាំងដែរ ។

ព្រឹកនេះ ប្រហែលម៉ោងប្រាំពីរ លោកមណ្ឌល អង្គុយកត់ត្រាមុខជំនួញភ្លុក កុយរមាស ស្បែកខ្លានៅក្នុងរោងដោយប្រកបទឹកមុខក្រៀមក្រំ ចោលកន្ទុយភ្នែកម្តងៗទៅក្រៅ ។ សូរជើងសេះ កុប កុប ៗ ចូលមកក្នុងភូមិ ។ នារីលោតចុះ នារីលោតចុះពីខ្នងសេះ ។

-ពុក ! ពុក ! ពុក ! ខ្ញុំមកវិញហើយពុក !

លោកមណ្ឌល ភ្លឹកស្មារតី ជ្រុះដងប៉ាកកាពីដៃស្ទុះចាប់ត្រកងបុត្រី យំសោកទាំង ២ នាក់ ។

-កូនមាសឪពុក ! កូនទៅដល់ណាចោលពុកយ៉ាងហ្នឹងកូន ?

-ចាំ ! កូនសូមទោសពុក កូនខុសហើយ កូនរត់តាមប្រុសដោយស្រឡាញ់គេជ្រុលពេក ឥឡូវកូនមករស់នៅជាមួយពុកវិញហើយ !

-កូនរត់តាមប្រុស . . . កូនមកនៅជាមួយពុកវិញ . . . អ្ហា ! ប្រសើរហើយកូន . . . ចុះប្តីកូនវានៅឯណា ?

-ចាំ ! គេត្រូវម្តាយគេបង្ខំឱ្យយកប្រពន្ធថ្មីមួយទៀត . . . ប៉ុន្តែ គេពុំចោលរូបកូនទេ មុខជាមកតាមពុំខានឡើយនៅពេលខាងមុខ ព្រោះខ្ញុំមកនេះលួចរត់ចេញ. . . ហើយនាងដែលមកជាមួយជាប្អូនថ្លៃរបស់ខ្ញុំ សូមពុកទទួលស្គាល់រក្សានាងផង. . . នាងស្មោះត្រង់ស្រឡាញ់ខ្ញុំណាស់ ។

-អើ ! នាងកួយមកអង្គុយក្បែរអ៊ុំមក !

សារឿន អង្គុយក្បែរលោកមេកន្ទ្រាញយុកណាំល្បែរ ។

ពេលនោះ លោកមណ្ឌល វាយស្គរប្រមូលកូនឃុំឱ្យមកជុំគ្នាដើម្បីប្រកាសថា បុត្រីរបស់គាត់មកវិញហើយ ។ ១៥ នាទី ក្រោយមកបណ្ដាជនមកឈររកកកុញមីដេរដាសពេញបរិវេណ ។ លោកមណ្ឌល នាំបុត្រីទៅឈរលើវេទិកាបង្ហាញបណ្ដារាស្ត្រ :

-លោកទាំងអស់គ្នា ! កូនស្រីខ្ញុំមកវិញហើយ នាងមានទាំងនារីម្នាក់ជាបរិវារមកជាមួយផង ។ ល្ងាចនេះសូមបណ្ដាជនទាំងអស់រក ទាក់ជ្រូក ទាក់ឈ្លូស មកស៊ីផឹកសប្បាយ ។ ព្រឹកស្អែកយើងដង្ហែរកូនយើងទៅសុំទោសដល់អ្នកតាចាំស្រុក ដល់ព្រះគ្រូព្រៃភ្នំ ។

លោកមណ្ឌល ប្រកាសចប់ ស្គរទះដៃអបអរសាទរ ញាំពងព្រៃព្រឹក្សា ។ បណ្ដាកូនឃុំរត់បែកខ្ញែកគ្នា ខ្លះរកជ្រូក ខ្លះបាញ់ឈ្លូស ប្រើស យកមកជប់លៀងសប្បាយ នឹងសុំទោសដល់អ្នកតាចាំស្រុក ។

. . . . . . . . . . . . . . . . . . . . . . . . . . . . . .

ម្ដងនេះ សូមមិត្តអ្នកអានមេត្តាចោលភ្នែកទៅផ្សារអូររាំងម្ដង ។

-សារឿន ! សារឿន អាំ ! យីទៅណាអស់អីចឹង ?

មីងតៅ ហៅបុត្រី ។ សូផាន ច្រានទ្វារចូលរកគ្រប់ច្រកល្ហកពុំឃើញ ។

-ម៉ាក់ ! ម៉ាក់ យី ប្រពន្ធខ្ញុំ ទៅណាអស់ហើយ. . . ប្អូនសារឿន ក៏បាត់ដែរ . . . ! អូនមណ្ឌលគីរីអើយ ! អូនគីរី !

ទោះបីជនទាំង ២ ហៅយ៉ាងណាក៏គ្មានឮចម្លើយផង ។

-ម៉ាក់ ! ប្រពន្ធខ្ញុំប្រាកដជារត់ទៅនៅជាមួយឪពុកនាងវិញហើយ !

-អើ ! ឱ្យវាទៅចុះ កូនឯងនៅជាមួយម៉ាក់ ម៉ាក់នឹងរៀបការឆាប់ៗនេះពុំខាន ។ មីសារឿន បើវាចិត្តដាច់ពីម៉ែពីឪហើយកុំគិតវា កាត់កាល វាមួយចោលទៅ កុំទៅតាមវាមួយជំហាន ។ គង់តែថ្ងៃណាមួយវាត្រឡប់វិលវិញទេ ។

សូផាន យំសោកបោកខ្លួនដូចអកព្រាត់គូ រហូតលង់លក់ឥតដឹងខ្លួន ។

ឯមីងតៅវិញ ចិត្តកំហឹងពុះពេញទ្រូងខ្ពាញ់នឹងបុត្រីដែលរត់ចោលគាត់ ។ បន្ទាប់មក គាត់ស្លៀកពាក់ជាថ្មី ប្រញាប់ប្រញាប់ទៅរកគ្រូអាចារ្យដេញលេខអត្ត: រកវេលាល្អរៀបការ សូផាន នឹង កញ្ញា សារុន នៅក្រុងក្រចេះ ។

## ៧-ព្រាត់ស្នេហ៍នៅមណ្ឌលគិរី

មួយខែកន្លងមក...។ សូផាន បានរៀបការជាមួយ កញ្ញា សារុន។ រៀងរាល់ទិវារាត្រី អ្នកតែងតែអង្គុយនឹងមមៃដល់មណ្ឌលគិរី។ ជូនកាលបុរសដេកយំសោកតែឯង។ ទោះបីភរិយាថ្មីលួងលោម ជជីកសួរហេតុផលយ៉ាងណា សូផាន មិនបានប្រាប់រឿងរបស់គេទេ គេកុហកភូតឱ្យតែរួចពីមាត់។ មិនយូរប៉ុន្មាន រូបកាយសូផានស្គាំងស្គម ស្បែកលឿង ភ្នែកស្លក់រហូតធ្លាក់ខ្លួនមានជម្ងឺជាទម្ងន់។

ថ្ងៃមួយ សូផាន អង្គុយហាលក្ដៅកុំឱ្យរងានៅមុខផ្ទះ ឃើញនារីម្នាក់ជិះសេះតម្រង់ចូលមករកជិតឡើងៗ ។ បុរសយកដៃឈ្លីភ្នែកខំសម្លឹងមើល។

-អូនសារឿន ! អូនសារឿនមកវិញហើយ !

-បងផាន ! បងផាន ! បងផាន ព្រឹកមិញនេះបងគីរីរៀបការជាមួយកូនលោកមេកន្ទ្រាញកោះញ៉ែករួចទៅហើយ !

-គីរីរៀបការជាមួយកូនលោកមេកន្ទ្រាញកោះញ៉ែក ?

-ចាំ ! បងអញ្ជើញឱ្យឿនទៅ ជួយយកបងគីរីមកវិញ !។

ភ្លាមនោះ សូផាន ហាក់ជាស្បើយក្នុងខ្លួនអស់រលីង។ បុរសស្ទៀកពាក់ឡើងបំផាយសេះជាមួយ សារឿន ទៅរកភ្នំយុកណាំលៀវ។ អ្នកបំបោលសេះគ្មានបង្អង់ដៃកាត់ព្រៃព្រឹក្សា ភ្នំ តូចធំ។

បើមើលទៅជើងភ្នំនោះវិញ គេឮតែស្គរ ភ្លេងការតាមទំនៀមទម្លាប់ប្រពៃណីរបស់ពួកភ្នំ។ ស្នូរស្នែងលាយនឹងគងឃ្មោះទ្រហឹងអឺងកង។

រាត្រីយាងមកដល់ ព្រះចន្ទថ្ងៃពេញបូរណមីរះភ្លឺថ្លា... ។ បណ្ដារាស្ត្រគ្រប់សាសន៍មាន មន ស្មៀង កួយ ភ្នង ជ្រាយ ជាដើមនាំគ្នាស៊ី ផឹកសប្បាយពេញបរិវេណគេហស្ថាន លោកមណ្ឌល ។

នារីម្នាក់ ស្លៀកពាក់តាមប្រពៃណីអាពាហ៍ពិពាហ៍ លោតចេញតាមបង្អួចកាត់ស្បៃរាត្រី រត់តម្រង់ទៅរកទឹកស្ទឹងដែលនៅឆ្ងាយពីភូមិ ។

គីរីនឹកឃើញពាក្យសម្បថជាមួយសង្សារ ក៏លើកដៃសំពះទៅព្រះ ចន្ទដែលរះថ្លាក្រឡង់ ហាក់សម្លឹងមករករូបនាង ។ ស្រស់ស្រីឈរមើលខ្សែទឹកហូរថ្លាសែនជ្រៅ ។ នាងលើកដៃប្រកាសបួងសួងឡើងថា :

" សូមព្រះពុទ្ធជាម្ចាស់ ទេព្ដាទាំងមួយម៉ឺនលោកធាតុអារក្សព្រៃព្រឹក្សសូមជួយធ្វើជាសាក្សីនៃនាងខ្ញុំផង ។ នាងខ្ញុំសម្លាប់ខ្លួនវេលានេះ គឺគោរពតាមពាក្យសម្បថនៅវត្តកម្ពី កាលនាងខ្ញុំនឹងសូផានស្រឡាញ់គ្នាដំបូង សច្ចាថាមិនបែកចិត្តចោលគ្នាឡើយ ។ ឥឡូវមាតាបិតាបានឱ្យរៀបការនឹងគូថ្មីនាងខ្ញុំសុខចិត្តពីក្ស័យប្រល័យជីវិតតាមខ្សែជលសានេះហើយ ។ សូមព្រះអង្គជួយនាំព្រលឹងនាងខ្ញុំទៅចាប់ភពថ្មីរង់ចាំបងសូផានកុំបីខាន ។ នារីបួងសួងរួចសង្រួមកាយ វាចាចិត្ត វិញ្ញាណលោតប្រូងសម្លាប់ខ្លួនទៅក្នុងជលសាដ៏សែនជ្រៅ ។ ខ្សែទឹកកួចត្រឡប់ត្រឡិនកាយស្រីផ្ដាច់សង្ខារក្នុងវេលានោះឯង ។ មិនយូរប៉ុន្មាន រូបកាយស្រីអណ្ដែតទៅកឿងជាប់មាត់ ជ្រោះមួយក្រោមដើមជ្រៃធំ ក្បែរទីទួលដ៏ខ្ពស់ ។"

រីឯអ្នកស្រុកជើងភ្នំយុកណាំល្បៀវ កាលបើបាត់សាមីខ្លួនស្រីក្នុងអាពាហ៍ពិពាហ៍ហើយ ក៏ចាត់មនុស្ស កងកម្លាំងដើររកទាំងយប់ជ្រៅ ។ ខ្លះចុះរាវក្នុងអណ្ដូង ស្រះ ខ្លះរកគ្រប់ដើមឈើ ក្រែងនាងចងកសម្លាប់ ។

ទោះបីខំរាវរកយ៉ាងណា ពុំបានទទួលលទ្ធផលឡើយ ។ មួយយប់ ទល់ភ្លឺ គេរកប្រសេចប្រសាចពេញព្រៃភ្នំ ។

ព្រះអាទិត្យរះភ្លឺច្បាស់ បំភ្លឺពេញចក្រវាឡ ។ ខ្សែជីវិតទារុណទាំងទ្វេ បំផាយអាជានេយ្យដល់ម្លប់ដើមជ្រៃ ដើម្បីសម្រាកកំឡាំងលុបមុខ លាងភ្នែកឱ្យជ្រះស្រឡះ ។ សូផាន ចងសេះឱ្យឈរ អ្នកចុះទៅក្បង់ទឹកលុបមុខ ។ ស្រាប់តែប្រទះសាកសពគិរី ។

-អូនគិរី ! អូនគិរី ! ហ៊ឺ. . . ហ៊ឺ. . . ហ៊ឺ អូនគិរីស្លាប់ចោលបងហើយ ! ។ សារឿន ភ្ញាក់រន្ធត់ចិត្តស្ទុះទៅមើលឃើញ សូផានត្រកងសពគិរីឡើងគោក ។

សារឿនស្រែកយំផ្ងោង១ ជួយត្រកងសពបងថ្លៃ ។ គេយករូបកាយគិរីដាក់ផ្តេកក្រោមដើមជ្រៃ ទឹកភ្នែកហូរហៀរជោកថ្ពាល់ ។

-អូនសារឿន ឱ្យលឿនទៅអូន ជំរាបលោកមេកន្ទ្រាញឱ្យជ្រាប ។

-ចាំ ! បងនៅថែសពចុះ ខ្ញុំទៅហើយ ។

សារឿនចេញផុតទៅ សូផានឱបថើបសាកសពយំបង្ហូរនទៀល លើកាយអសុក ។ បន្ទាប់មកគេប្រវ៉ាឡើងដើមជ្រៃ សួរទៅរកមែកយ៉ាងខ្ពស់មួយ ឈរសំឡឹងមកសាកសពសង្សារខាងក្រោមខ្ពស់ស្រឡូង ។ បុរសលើកដៃបួងសួងប្រកាសដល់ ទេព្តា ព្រះឥន្ទ ព្រះព្រហ្ម រួចលោត សម្លាប់ខ្លួនមកក្រោមប្រាវ ។ រាងកាយបុរសធ្លាក់បាក់ក ខ្ទេចខ្ទីឆ្អឹងជំនីរ ដេកស្តូកស្តឹងស្លាប់ទន្ទឹមគ្នាខ្មោចលង់ទឹក ។ ឈាមក្រហមហូរចេញពីមាត់ ពីច្រមុះ ដល់ក្តីមរណៈគ្រានោះឯង ។

ប្រាំនាទីក្រោយមក លោកមេកន្ទ្រាញ មណ្ឌល នឹងបរិវាររត់មកដល់ ។ ឈរគោរពវិញ្ញាណក្ខណអ្នកទាំង ២ ដោយស្ងៀមស្ងាត់ ។

បន្ទាប់មក គេលុតជង្គង់វន្ទាសពព្រម១គ្នា លើកដៃសំពះទៅលើ សូត្រធម៌ ផ្លុំស្នែង វាយគង រគាំង ប្រកាសថាមានមនុស្សស្លាប់។

ពិធីធ្វើបុណ្យបញ្ជូនវិញ្ញាណក្ខន្ធដល់គូសង្សារ ក៏ចាប់ផ្ដើមនៅលើទីទួលក្រោមដើមជ្រៃ ប្របមាត់ស្ទឹងអស់រយៈ ៣ ថ្ងៃ ។ គេកប់ខ្មោចទាំង ២ ក្នុងរណ្ដៅផ្នូរតែមួយ។ ខណៈនោះគេឃើញលោក មណ្ឌល នឹង កញ្ញា សារឿន ស្លៀកពាក់តាមប្រពៃណីកាន់ទុក្ខ ដល់គូភរិយាចិត្តស្មោះត្រង់ ដែលរំលាយខន្ធទៅចាប់ភពថ្មីនាជាតិខាងមុខ។

ពិធីបុណ្យបញ្ជូនមគ្គផលក៏បានចប់សព្វគ្រប់ គេដកខ្លួនថយចេញពីផ្នូរខ្មោចសន្សឹម១ យ៉ាងស្ងៀមស្ងាត់។ បក្សាបក្សី ហើរទាំងគូ១ ញីឈ្មោល ចេញពីទ្រុងដែលគេដាក់លែងឱ្យហើរ នៅក្បែរផ្នូរខ្មោច។

## ~អវសាន~

ពេលនោះ លោកតាខ្មៅនិទានរឿងចប់ហើយ ព្រះសុរិយាក៏ទាបចតចុះរករូងភ្នំ។ ខ្ញុំបាទជាភ្នាក់ងារទាហានមួយរូប ក្រោកឈរគោរពវិញ្ញាណក្ខន្ធផ្នូរខ្មោច រួចសំពះលាបងប្អូនខ្មែរលើវិលទៅរកជំរំកងវិញ។ ខ្ញុំដើរបណ្ដើរ គិតបណ្ដើរ គិតថានឹងយករឿងដ៏ខ្លោចផ្សារប្រហែលរឿង ទុំទាវ ដែរនោះ មកចងក្រងជាកម្រងរឿងឡើងទុកជូនដល់មិត្តអ្នកអានទូទៅឱ្យបានជ្រាបរឿងដ៏ល្អនៅមណ្ឌលគីរីជំនាន់ដើម។

ដូច្នេះ ទោះបីការចងក្រងនិពន្ធរបស់ខ្ញុំបាទក្នុងរឿងព្រាត់ស្នេហ៍នៅមណ្ឌលគិរី ពុំក្បោះក្បាយ ខុសឆ្គងត្រង់ណា សូមអស់លោកអ្នកនាងអានមេត្តាអភ័យទោសឱ្យទាន ! ។

សូមអរគុណ !

សរសេរចប់នៅមណ្ឌលគិរី ថ្ងៃ ១៨ កក្កដា ១៩៦៥

អ្នកនិពន្ធ ប្រាជ្ញ-សេង

# ចប់